ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ១៦៣ ប្រក.កសក

# ប្រកាស
# ស្តីពី
# វិធានកសិកម្មសរីរាង្គកម្ពុជា និងរូបសញ្ញាជាតិ សម្រាប់អនុវត្តក្នុងផលិតកម្ម និងការកែច្នៃបឋមដំណាំស្បៀង

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងគុណភាពសុវត្ថិភាពលើផលិតផលទំនិញ និងសេវា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៥ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារ ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមាន



អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣-២១៧ ៣២០
Phone: (023) 726 128 / 726 129, Fax: (855) 23-217 320

ថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានកៅស៊ូ...

- បានឃើញអនុក្រឹត្យលេខ១៧៩ អនក្រ.បក ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការបង្កើតនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម ចំណុះអគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ស្តីពីការដំឡើងនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល ទៅជាអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ
- បានឃើញអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការកែសម្រួលមាត្រា២ មាត្រា២៥ មាត្រា២៦ និងមាត្រា៣៥ នៃអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ និងមាត្រា២៧ថ្មី នៃអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៧
- បានឃើញអនុក្រឹត្យលេខ១៦៣ អនក្រ.បក ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានពូជដំណាំចំណុះអគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញប្រកាសលេខ៣៣៤ ប្រក.កសក.ប ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០៧ ស្តីពីការត្រួតពិនិត្យសុវត្ថិភាពចំណីអាហារនៃផលិតផលកសិកម្ម
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងកំណត់វិធានកសិកម្មសរីរាង្គកម្ពុជា និងរូបសញ្ញាជាតិសម្គាល់ការអនុវត្តវិធានកសិកម្មសរីរាង្គកម្ពុជាសម្រាប់ប្រើប្រាស់ក្នុងផលិតកម្ម និងការកែច្នៃបឋមដំណាំស្បៀង និងការធ្វើពាណិជ្ជកម្មផលិតផលកសិកម្មសរីរាង្គ។

**ប្រការ២.-**

ប្រកាសនេះមានគោលដៅ៖

- លើកកម្ពស់ការជឿជាក់ចំពោះអ្នកផលិត និងអ្នកប្រើប្រាស់ផលិតផលកសិកម្មធ្វើជាចំណីអាហារប្រកបដោយគុណភាព និងសុវត្ថិភាព
- លើកកម្ពស់ និងគាំទ្រការចូលរួមរបស់ប្រជាកសិករ សហគមន៍កសិកម្ម និងផ្នែកឯកជន ដើម្បីជំរុញការអនុវត្តវិធានកសិកម្មសរីរាង្គកម្ពុជានៅក្នុងផលិតកម្ម និងការកែច្នៃបឋមដំណាំស្បៀង
- លើកកម្ពស់គុណភាព និងសុវត្ថិភាពកសិផលស្របតាមស្តង់ដារផលិតផលកសិកម្មសរីរាង្គ ដើម្បីបង្កើនឧត្តមភាពប្រកួតប្រជែង និងជំរុញពាណិជ្ជកម្មផលិតផលស្បៀង នៅលើទីផ្សារក្នុងស្រុក និងសម្រាប់ការនាំចេញ
- រួមចំណែកគាំពារបរិស្ថាន ថែរក្សាសុខភាព សុវត្ថិភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ។

**ប្រការ៣.–**

ប្រកាសនេះមានវិសាលភាពគ្របដណ្តប់ ចំពោះការអនុវត្តកសិកម្មសរីរាង្គនៅក្នុងផលិតកម្ម និងការកែច្នៃបឋមដំណាំស្បៀង និងចំពោះផលិតផលកសិកម្មសរីរាង្គដែលធ្វើពាណិជ្ជកម្មរួមមាន ផ្លែឈើ បន្លែ និងដំណាំស្បៀងផ្សេងៗទៀត។

**ប្រការ៤.–**

វិធានកសិកម្មសរីរាង្គកម្ពុជា ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី១ និងគំរូរូបសញ្ញាជាតិសម្គាល់ការអនុវត្តវិធានកសិកម្មសរីរាង្គកម្ពុជា ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី២នៃប្រកាសនេះ។

**ប្រការ៥.–**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លើកទឹកចិត្តចំពោះការចូលរួមរបស់ប្រជាកសិករ សហគមន៍កសិកម្ម និងផ្នែកឯកជន ដែលធ្វើការដាំដុះដំណាំស្បៀង ដើម្បីធ្វើពាណិជ្ជកម្មផលិតផលស្បៀង តាមរយៈការផ្តល់សេវាអប់រំ និងតម្រង់ទិសអនុវត្តវិធានកសិកម្មសរីរាង្គកម្ពុជា ដើម្បីធានាបានថា ផលិតផលស្បៀងទាំងនោះមានគុណភាពល្អ និងមានសុវត្ថិភាពសម្រាប់ការប្រើប្រាស់ជាចំណីអាហាររបស់មនុស្ស ឬចំណីសត្វ។

**ប្រការ៦.–**

អគ្គនាយកដ្ឋានកសិកម្មទទួលបន្ទុករៀបចំ និងអនុវត្តប្រព័ន្ធយន្តការបច្ចេកទេសនិងគ្រប់គ្រងសម្រាប់ការអនុវត្តវិធានកសិកម្មសរីរាង្គកម្ពុជានៅក្នុងផលិតកម្មដំណាំស្បៀង រហូតដល់ការលាងសម្អាត វេចខ្ចប់ផលិតផលស្រស់ ព្រមទាំងការប្រើប្រាស់រូបសញ្ញាជាតិនៅលើផលិតផលស្បៀង ដែលមានប្រភពចេញពីការអនុវត្តវិធានកសិកម្មសរីរាង្គកម្ពុជា។

នាយកដ្ឋានកសិ-ឧស្សាហកម្មទទួលបន្ទុករៀបចំ និងអនុវត្តប្រព័ន្ធយន្តការបច្ចេកទេស និងគ្រប់គ្រងសម្រាប់ការអនុវត្តវិធានកសិកម្មសរីរាង្គក្នុងខ្សែច្រវាក់កែច្នៃបឋមដំណាំស្បៀង ក្រោយការលាងសម្អាត វេចខ្ចប់ផលិតផលស្រស់ ព្រមទាំងការប្រើប្រាស់រូបសញ្ញាជាតិនៅលើផលិតផលស្បៀង ដែលមានប្រភពចេញពីការអនុវត្តវិធានកសិកម្មសរីរាង្គកម្ពុជាក្នុងខ្សែច្រវាក់កែច្នៃបឋមដំណាំស្បៀងនេះ។

**ប្រការ៧.–**

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលអនុវត្តកសិកម្មសរីរាង្គនៅក្នុងផលិតកម្ម និងការកែច្នៃបឋមដំណាំស្បៀង ត្រូវធានាគុណភាពផលិតផល និងអាចប្រើប្រាស់ស្លាកសញ្ញាសម្គាល់ផលិតផលរបស់ខ្លួនដោយផ្ទាល់ប្រកបដោយតម្លាភាពនិងភាពទុកចិត្ត ដោយអនុលោមតាមនីតិវិធីប្រព័ន្ធធានាដោយមានការចូលរួម។

**ប្រការ៨.–**

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានបំណងផ្តល់សេវាធានាការអនុវត្តកសិកម្មសរីរាង្គ ដើម្បីធ្វើពាណិជ្ជកម្មផលិតផលស្បៀង ដែលមានប្រភពចេញពីការអនុវត្តកសិកម្មសរីរាង្គ ឬមានបំណងប្រើប្រាស់រូបសញ្ញាជាតិសម្គាល់ការអនុវត្តវិធានកសិកម្មសរីរាង្គកម្ពុជា ដើម្បីបញ្ជាក់លើផលិតផលសរីរាង្គ ត្រូវដាក់ពាក្យស្នើសុំការទទួលស្គាល់ពីអគ្គនាយកដ្ឋានកសិកម្ម ឬនាយកដ្ឋានកសិ-ឧស្សាហកម្មស្របតាមតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់អង្គភាពទាំងពីរដូចមានចែងក្នុងប្រការ៦។

**ប្រការ៩.-**

អគ្គនាយកដ្ឋានកសិកម្ម ឬនាយកដ្ឋានកសិ-ឧស្សាហកម្ម ត្រូវចាត់តាំងភ្នាក់ងារបច្ចេកទេសពាក់ព័ន្ធ ដើម្បីចុះពិនិត្យ និងវាយតម្លៃលើការអនុវត្តវិធានកសិកម្មសរីរាង្គកម្ពុជាក្នុងផលិតកម្ម និងការកែច្នៃបឋមដំណាំស្មៀង ស្របតាមតួនាទី និងភារកិច្ចដូចមានចែងក្នុងប្រការ៦ តាមការស្នើសុំរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលសាមី។

គំរូពាក្យស្នើសុំ និងសំណុំបែបបទសម្រាប់ការវាយតម្លៃការអនុវត្តវិធានកសិកម្មសរីរាង្គកម្ពុជា ត្រូវកំណត់ដោយអគ្គនាយកដ្ឋានកសិកម្ម និងនាយកដ្ឋានកសិ-ឧស្សាហកម្ម។

**ប្រការ១០.-**

ក្នុងករណីការវាយតម្លៃលើផលិតកម្ម និងការកែច្នៃបឋមដំណាំស្មៀង ទទួលបានលទ្ធផលវិជ្ជមាន ស្របតាមលក្ខខណ្ឌតម្រូវនៃវិធានកសិកម្មសរីរាង្គកម្ពុជា អគ្គនាយកដ្ឋានកសិកម្ម ឬនាយកដ្ឋានកសិ-ឧស្សាហកម្ម ត្រូវផ្តល់វិញ្ញាបនបត្របញ្ជាក់ការទទួលស្គាល់ការអនុវត្តវិធានកសិកម្មសរីរាង្គកម្ពុជា ស្របតាមតួនាទី និងភារកិច្ចដូចមានចែងក្នុងប្រការ៦ និងអនុញ្ញាតឱ្យរូបវន្តបុគ្គល ឬនីតិបុគ្គលដែលស្នើសុំ មានសិទ្ធិប្រើប្រាស់រូបសញ្ញាជាតិសម្គាល់ការអនុវត្តវិធានកសិកម្មសរីរាង្គកម្ពុជាលើផលិតផលរបស់ខ្លួន។

**ប្រការ១១.-**

វិញ្ញាបនបត្របញ្ជាក់ការទទួលស្គាល់ការអនុវត្តវិធានកសិកម្មសរីរាង្គកម្ពុជា ត្រូវបានកំណត់រយៈពេលសុពលភាពអាស្រ័យទៅតាមផលិតកម្ម ឬស្របតាមវដ្តរដាំដុះនៃប្រភេទដំណាំ ដែលកំណត់ដោយកាលបរិច្ឆេទជាក់លាក់។

រូបសញ្ញាជាតិស្តីពីការអនុវត្តវិធានកសិកម្មសរីរាង្គកម្ពុជា ដែលអនុញ្ញាតឱ្យប្រើប្រាស់ ឬបិទសម្គាល់លើផលិតផល ត្រូវបានកំណត់ចំនួនជាក់ស្តែងស្របតាមទំហំផលិតកម្ម ឬបរិមាណផលិតផល ដែលបានត្រួតពិនិត្យ និងវាយតម្លៃ។

**ប្រការ១២.-**

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលស្នើសុំការទទួលស្គាល់ការអនុវត្តវិធានកសិកម្មសរីរាង្គកម្ពុជាក្នុងផលិតកម្ម និងការកែច្នៃបឋមដំណាំស្មៀង និងការប្រើប្រាស់រូបសញ្ញាជាតិសម្គាល់ការអនុវត្តវិធានកសិកម្មសរីរាង្គកម្ពុជា ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- ត្រូវចូលរួមវគ្គបណ្តុះបណ្តាលស្តីពីវិធានកសិកម្មសរីរាង្គកម្ពុជា
- ត្រូវអនុវត្តតាមគោលការណ៍ណែនាំបច្ចេកទេសកសិកម្មសរីរាង្គ
- ត្រូវឆ្លងកាត់ដំណើរការវាយតម្លៃដោយក្រុមភ្នាក់ងារបច្ចេកទេស នៃអគ្គនាយកដ្ឋានកសិកម្ម ឬនាយកដ្ឋានកសិ-ឧស្សាហកម្ម ស្របតាមតួនាទី និងភារកិច្ចរបស់អង្គភាពទាំងពីរដូចមានចែងក្នុងប្រការ៦ ឬអង្គភាពពាក់ព័ន្ធផ្សេងទៀត លើការអនុវត្តវិធានកសិកម្មសរីរាង្គកម្ពុជា។

កម្រៃសេវាសាធារណៈ លើការវាយតម្លៃកសិកម្មសរីរាង្គកម្ពុជា ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ប្រការ១៣.-**

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលកាន់កាប់វិញ្ញាបនបត្របញ្ជាក់ការទទួលស្គាល់ការអនុវត្តវិធានកសិកម្ម

សរីរាង្គកម្ពុជា ត្រូវធានាចំពោះគុណភាព និងសុវត្ថិភាពផលិតផលរបស់ខ្លួន ឬទទួលខុសត្រូវក្នុងការប្រើប្រាស់រូបសញ្ញាជាតិសម្គាល់ការអនុវត្តវិធានកសិកម្មសរីរាង្គកម្ពុជា នៅលើផលិតផលរបស់ខ្លួន ស្របតាមបទប្បញ្ញត្តិនៃប្រកាសនេះ។

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើសកម្មភាពលើផលិតកម្ម និងការកែច្នៃបឋមដំណាំស្បៀង ឬធ្វើពាណិជ្ជកម្មផលិតផលស្បៀង ដោយក្លែងបន្លំគុណភាពផលិតផលកសិកម្មសរីរាង្គ ក្លែងបន្លំរូបសញ្ញាជាតិសម្គាល់ការអនុវត្តវិធានកសិកម្មសរីរាង្គកម្ពុជា ឬប្រើប្រាស់រូបសញ្ញាជាតិក្លែងបន្លំសម្គាល់ការអនុវត្តវិធានកសិកម្មសរីរាង្គកម្ពុជា ត្រូវទទួលទោសតាមច្បាប់ពាក់ព័ន្ធជាធរមាន។

**ប្រការ១៤.-**

វិធានកសិកម្មសរីរាង្គកម្ពុជា ដែលកំណត់ក្នុងឧបសម្ព័ន្ធទី១នៃប្រកាសនេះ អាចធ្វើការកែប្រែបានតាមការចាំបាច់ដោយអនុលោមតាមលទ្ធផលស្រាវជ្រាវ និងបច្ចុប្បន្នភាពនៃលក្ខខណ្ឌតម្រូវក្នុងក្របខ័ណ្ឌជាតិ តំបន់ ឬសកល។

**ប្រការ១៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៦.-**

អគ្គលេខាធិការ អគ្គាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម ប្រធាននាយកដ្ឋានកសិ-ឧស្សាហកម្ម ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។ KHS

ថ្ងៃព្រហស្បតិ៍ ៩រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស ២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២០

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី១នៃប្រកាសលេខ១៦៣........ប្រក.កសក ចុះថ្ងៃទី១៦.ខែឧសភា.ឆ្នាំ២០២០

## ស្តីពីវិធានកសិកម្មសរីរាង្គកម្ពុជា
## សម្រាប់អនុវត្តក្នុងផលិតកម្ម និងការកែច្នៃបឋមដំណាំស្បៀង

# វិធានកសិកម្មសរីរាង្គកម្ពុជា

### សេចក្តីផ្តើម

ផលិតកម្មកសិកម្មតាមលក្ខណៈប្រពៃណីនៅក្នុងព្រះរាជាណាចក្រកម្ពុជាមានមូលដ្ឋានចម្បងផ្អែកលើគោលការណ៍សរីរាង្គ។ ការយល់ដឹងរបស់កសិករទាក់ទងទៅនឹងវិសាលភាពនៃការប្រើប្រាស់ជី និងការការពារដំណាំតាមគោលការណ៍ជីវសាស្ត្រត្រូវបានបង្កើន និងធ្វើឱ្យប្រសើរឡើងពីជំនាន់មួយទៅជំនាន់មួយ ហើយកសិករនៅតែអាស្រ័យលើបច្ចេកទេសទាំងអស់នេះ នៅក្នុងផលិតកម្មកសិកម្ម។

ប្រព័ន្ធផលិតកម្មកសិកម្មសរីរាង្គ មានមូលដ្ឋានផ្អែកទៅលើការប្រើប្រាស់ធនធានធម្មជាតិ ធនធានជីវសាស្ត្រ ធនធានកកើតឡើងវិញ និងធនធានបង្កើតថ្មី ក្នុងនោះកសិកម្មសរីរាង្គអាចជួយរក្សាជីជាតិដីតាមរយៈការប្រើប្រាស់សារធាតុសរីរាង្គកើតឡើងវិញ និងអាស្រ័យទាំងស្រុងទៅលើសកម្មភាពរបស់មីក្រូសរីរាង្គដែលរស់នៅក្នុងដី ហើយសត្វល្អិត ជំងឺ និងស្មៅចង្រៃត្រូវបានគ្រប់គ្រងតាមរយៈការអនុវត្តបច្ចេកទេសដាំដុះ។

ចំណីអាហារសរីរាង្គ និងអាហារផ្សេងទៀត ត្រូវបានផលិតពីធាតុផ្សំជាច្រើន ដែលមានប្រភពមកពីសរីរាង្គ ហើយត្រូវបានយកមកកែច្នៃដោយប្រើមធ្យោបាយជីវសាស្ត្រមេកានិច និងរូបសាស្ត្រខុសៗគ្នា ដែលជាហេតុនាំឱ្យមានការបែងចែករវាងប្រព័ន្ធកសិកម្មតាមគោលការណ៍សរីរាង្គ និងប្រព័ន្ធកសិកម្មតាមលក្ខណៈប្រពៃណី ហើយបរិមាណផលិតផលសរីរាង្គកំពុងត្រូវបានលើកកម្ពស់នៅលើទីផ្សារ។ បច្ចុប្បន្នការយល់ដឹង និងការលើកកម្ពស់ការដាំដុះតាមគោលការណ៍សរីរាង្គនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក៏ត្រូវបានពង្រឹងនិងពង្រីកយ៉ាងឆាប់រហ័សនៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។

សារៈសំខាន់នៃការអនុវត្តកសិកម្មសរីរាង្គ បានរួមចំណែកនៅក្នុងស្ថិរភាពសេដ្ឋកិច្ច សង្គម និងបរិស្ថានដូចជា៖

## ១-ចិរភាពនៃប្រព័ន្ធអេកូឡូស៊ីបរិស្ថាន

- ប្រើប្រាស់សារធាតុចិញ្ចឹមឡើងវិញជំនួសឱ្យការដាក់បញ្ចូលនូវសារធាតុពីខាងក្រៅ
- បង្ការការបំពុលពីសារធាតុគីមីទៅលើដី ទឹក និងខ្យល់
- ជំរុញឱ្យមានជីវសាស្ត្រចំរុះសម្បូរបែប
- កែលម្អដីជាតិដី និងបង្កើតនូវសារធាតុមមោគបានច្រើន
- បង្ការការហូរច្រោះដី និងការហាប់ដី
- ជំរុញឱ្យមានការប្រើប្រាស់ថាមពលកកើតឡើងវិញ។

## ២-ចិរភាពសង្គម

- គាំទ្រឱ្យមានផលិតកម្មគ្រប់គ្រាន់សម្រាប់ចិញ្ចឹមជីវិត និងការស្វែងរកប្រាក់ចំណូល នៅតាមគ្រួសារកសិករ
- ផ្តល់ស្បៀងអាហារប្រកបដោយសុវត្ថិភាព និងសុខភាព
- គាំទ្រដល់ការទទួលយកលក្ខខណ្ឌការងារធ្វើល្អៗ
- កសាងសមត្ថភាពនៅតាមមូលដ្ឋាន និងរក្សាចំណេះដឹងប្រពៃណី។

## ៣-ចិរភាពសេដ្ឋកិច្ច

- ជួយកសិករទទួលបានទិន្នផលប្រកបដោយភាពជឿជាក់ និងពេញចិត្ត
- កាត់បន្ថយចំណាយថ្លៃដើមផលិតកម្ម ក្នុងការទិញសម្ភារកសិកម្មផ្សេងៗ សម្រាប់ការដាំដុះ
- លើកទឹកចិត្តការអនុវត្តប្រព័ន្ធកសិកម្មអតិផល តាមរយៈការដាំដុះប្រភេទដំណាំចម្រុះ និងការកែច្នៃនៅនឹងកន្លែង ដើម្បីបង្កើនប្រាក់ចំណូលនិងផលចំណេញ
- លើកកម្ពស់គុណភាពនៃផលិតផល ពង្រឹងការជ្រៀតចូល និងការប្រកួតប្រជែងទីផ្សារ កសិផលប្រកបដោយទំនុកចិត្ត និងមានតម្លៃខ្ពស់។

**វិធានកសិកម្មសរីរាង្គកម្ពុជានេះ ត្រូវបានបង្កើតឡើងក្នុងគោលបំណងដូចខាងក្រោម៖**

- គ្រប់គ្រងប្រព័ន្ធអេកូឡូស៊ីបរិស្ថានប្រកបដោយចិរភាព
- ជានាកម្រិតជីជាតិដីក្នុងប្រព័ន្ធអេកូឡូស៊ីបរិស្ថាន ផ្អែកលើមូលដ្ឋានជីវសាស្ត្ររយៈពេលវែង
- ធ្វើការកាត់បន្ថយ ឬលុបបំបាត់នូវការប្រើប្រាស់ធាតុចូលជាសារធាតុគីមីសំយោគ នៅគ្រប់ដំណាក់កាលនៃខ្សែច្រវាក់ផលិតកម្មសរីរាង្គ និងការពារសុខភាពមនុស្សនិងបរិស្ថាន ពីគ្រោះថ្នាក់ដែលបង្កឡើងដោយសារធាតុគីមីទាំងនោះ។
- ចៀសវាងការបំពុល ឬកាត់បន្ថយការបំពុល និងការខូចខាតក្នុងទីតាំងផលិតកម្ម ឬកែច្នៃ និងអេកូឡូស៊ីបរិស្ថាន ដែលបង្កឡើងដោយសកម្មភាពផលិតកម្ម ឬកែច្នៃទាំងនោះ។

- ចៀសវាងបាននូវបច្ចេកវិទ្យា ដែលអាចបង្កឱ្យមានគ្រោះថ្នាក់ គ្មានលក្ខណៈធម្មជាតិ និងគ្មានការធានាច្បាស់លាស់នៅក្នុងប្រព័ន្ធផលិតកម្ម។
- ផ្តល់អត្តសញ្ញាណសរីរាង្គ និងរក្សាបាននូវភាពសុទ្ធនៃលក្ខណៈសរីរាង្គនៅគ្រប់ដំណាក់កាលនៃខ្សែប្រវាក់ផ្គត់ផ្គង់។

## ផ្នែក ក៖ ផលិតកម្ម ការកែច្នៃបឋម និងស្លាកសញ្ញាផលិតផលកសិកម្មសរីរាង្គ

### ១. និយមន័យ

**កសិកម្មតាមទម្លាប់ (Conventional Agriculture)៖**

សំដៅលើប្រព័ន្ធផលិតកម្មកសិកម្ម ឬការអនុវត្តកែច្នៃកសិកម្មមួយដែលមិនឆ្លើយតបតាមវិធាន និងការអនុវត្តផលិតកម្មកសិកម្មសរីរាង្គ។

**កសិកម្មសរីរាង្គ (Organic Agriculture)៖**

សំដៅដល់ប្រព័ន្ធគ្រប់គ្រងផលិតកម្មកសិកម្ម ដែលជានានិរន្តរភាពនៃប្រព័ន្ធគ្រ្យេត្របរិស្ថាន ដែលជំរុញ និងលើកកម្ពស់ជីវចម្រុះ វដ្តជីវិត និងសកម្មភាពជីវសាស្ត្រដី ធានាសុវត្ថិភាពផលិតផល សុខភាព និងសុខុមាលភាពរបស់មនុស្ស និងសត្វ។ ប្រព័ន្ធនេះផ្អែកទៅលើការប្រើប្រាស់ធាតុចូលកសិកម្មតិចតួចបំផុត ដោយយកចិត្តទុកដាក់ខ្ពស់ទៅលើការអនុវត្តប្រតិបត្តិដែលជួយស្តារ ថែរក្សា និងកែលម្អភាពសុខដុមនៃប្រព័ន្ធអេកូឡូស៊ី ដោយប្រមូលផ្តុំអនុវត្តនូវវិធីសាស្ត្រ បទពិសោធន៍ ជាប្រពៃណី ចំណេះដឹងវិទ្យាសាស្ត្រនិង គំនិតច្នៃប្រឌិតថ្មីៗ។

**កសិដ្ឋាន (Farm)៖**

សំដៅដល់ក្បាលដីមួយឬច្រើន ឬទំហំដីសរុបដែលស្ថិតនៅក្រោមការកាន់កាប់ ឬគ្រប់គ្រងដោយកសិករមួយរូប ឬកសិករមួយក្រុម ព្រមទាំងរួមបញ្ចូលនូវសកម្មភាពនៃខ្សែច្រវាក់ផលិតកម្មកសិកម្មទាំងមូល។

**កសិផលសរីរាង្គ (Organic Produce)៖**

សំដៅដល់កសិផលទាំងឡាយដែលបានផលិត ឬប្រមូលផលពីធម្មជាតិ កែច្នៃ ទុកដាក់ ដឹកជញ្ជូន និងកាន់កាប់ដោយស្របតាមវិធានកសិកម្មសរីរាង្គកម្ពុជា។

**ការកែច្នៃ (Processing)៖**

សំដៅដល់ប្រព្រឹត្តកម្មឬការបំលែង ឬវេចខ្ចប់ផលិតផលកសិកម្ម ឬអនុផលដែលបានផលិត ឬប្រមូលពីធម្មជាតិ ដើម្បីទទួលបានផលិតផលកែច្នៃដែលមានទម្រង់ និងគុណភាពជាក់លាក់។

**ការកែច្នៃបឋម( Primary Processing )៖**

សំដៅដល់ការបំលែងវត្ថុធាតុដើមនៃផលិតផលកសិកម្ម ឬស្បៀងអាហារបន្ទាប់ពីបានធ្វើការប្រមូលផលរួម ដើម្បីរៀបចំជាអាហារសម្រាប់តម្រូវការប្រើប្រាស់ ឬប្រែក្លាយទៅជាផលិតផលផ្សេងទៀត។ ការកែច្នៃបឋមនេះ រាប់បញ្ចូលទាំងការវេចខ្ចប់ ដឹកជញ្ជូន ការធ្វើចំណាត់ថ្នាក់ ការសម្អាត ហាលសម្ងួត លាយផ្សំ កិន និងថែរក្សាស្តុកទុក។ល។

**ការដាំដំណាំឆ្លាស់ ( Inter-Cropping )៖**

សំដៅដល់ការដាំឆ្លាស់គ្នារវាងពូជដំណាំ ឬអំបូរដំណាំផ្សេងគ្នានៅលើផ្ទៃដីតែមួយ នៅក្នុងវដ្តប្រមូលផលតែមួយ តាមគម្រោងផែនការដាក់លាក់មួយ ដើម្បីទប់ស្កាត់ការឃាយីដោយសមាសភាពចង្រៃ ធ្វើឱ្យប្រសើរនូវកម្រិតជីជាតិដី នឹងអាចរក្សាប្រសិទ្ធភាពសេដ្ឋកិច្ចនៃផលដំណាំ ក្នុងករណីមានហានិភ័យណាមួយកើតឡើង។

**ការដាំដំណាំបង្វិល( Crop Rotation )៖**

សំដៅដល់ការដាំដុះដំណាំ ដែលតម្រូវឱ្យប្តូរពូជដំណាំ ឬអំបូរដំណាំនៅលើផ្ទៃដីតែមួយនៅក្នុងវដ្តប្រមូលផលខុសគ្នា ដោយមានផែនការដាំដុះដាក់លាក់ក្នុងគោលបំណងទប់ស្កាត់ ឬជួយកាត់បន្ថយការឃាយីដោយសមាសភាពចង្រៃ និងជួយកែលម្អគុណភាពដី។

**ការធ្វើអនាម័យ( Sanitizing )៖**

សំដៅដល់ប្រព្រឹត្តកម្មទាំងឡាយណា ដែលមានប្រសិទ្ធភាពបំផ្លាញឬកាត់បន្ថយយ៉ាងច្រើននូវកោសិកាលូតលាស់នៃមីក្រូសរីរាង្គដែលជាកង្វល់នៃសុខភាពសាធារណៈ និងមីក្រូសរីរាង្គចង្រៃផ្សេងៗទៀត។

**ការសម្លាប់មេរោគ ( Disinfection )៖**

សំដៅដល់ការកាត់បន្ថយអតិសុខុមប្រាណគ្រោះថ្នាក់ខ្លាំង នៅក្នុងបរិស្ថានរហូតដល់កម្រិតមួយ ដែលមិនប៉ះពាល់ដល់ភាពសមស្រប និងសុវត្ថិភាពចំណីអាហារ ដោយប្រើប្រាស់មធ្យោបាយគីមីសាស្ត្រ ឬរូបសាស្ត្រ។

**ការបង្កាត់ពូជ ( Breeding )៖**

សំដៅដល់ការជ្រើសរើសរុក្ខជាតិ ឬសត្វជាមេបាដើម្បីបន្តពូជបង្កើតបានជារុក្ខជាតិ ឬសត្វជំនាន់ថ្មី ដែលមានលក្ខណៈល្អប្រសើរជាងតាមការចង់បាន។

**ការបញ្ចាំងកាំរស្មី (Irradiation)៖**

សំដៅដល់បច្ចេកវិទ្យាប្រើប្រាស់ ការបញ្ចេញថាមពលខ្ពស់ពីវិទ្យុសកម្មនុយក្លេអូទីតដែលមានសមត្ថភាពធ្វើឱ្យប្រែប្រួលរចនាសម្ព័ន្ធម៉ូលេគុលនៃផលិតផល ក្នុងគោលបំណងត្រួតពិនិត្យពពួកមេរោគចម្លង ភ្នាក់ងារបង្កជំងឺ ប៉ារ៉ាស៊ីត និងសមាសភាពចង្រៃផ្សេងៗ ក្នុងផលិតផល (ជាទូទៅសំដៅដល់ចំណីអាហារ) ក្នុងការថែរក្សាគុណភាពផលិតផល ឬទប់ស្កាត់មុខងារសរីរៈសាស្ត្រ ដូចជាការចេញពន្លក ឬការឡើងទុំ។ ការបញ្ចាំងកាំរស្មីនេះ មិនរួមបញ្ចូលប្រភពពន្លឺមានកម្រិតទាបដូចជាការប្រើប្រាស់កាំរស្មីអ៊ិចសម្រាប់តាមដានរកវត្ថុចម្លែក។ បច្ចេកវិទ្យាបែបនេះក៏សំដៅដល់ការប្រើកាំរស្មីអ៊ីយ៉ុងដែរ ទោះបីនិយមន័យនៃពាក្យនេះក្នុង បរិបទបច្ចេកទេស និងច្បាប់មានលក្ខណៈខុសប្លែកគ្នាក៏ដោយ។

**ការប្រមូលផលពីធម្មជាតិ (Wild Harvest)៖**

សំដៅដល់ការប្រមូលយក និងផ្គុំផលិតផលពីទីតាំងមួយ ឬតំបន់មួយ ដែលមិនមានការថែទាំ ក្រោមការធ្វើវប្បកម្ម ឬការគ្រប់គ្រងសកម្មភាពកសិកម្មផ្សេងៗទៀត។

**ការដាក់ស្លាកសញ្ញា (Labelling)៖**

សំដៅដល់ការប្រើប្រាស់ស្លាកសញ្ញា ដែលបញ្ជាក់ព័ត៌មានពីផលិតផលសរីរាង្គក្រោមរូបភាពជាអក្សរសំណេរ រូបក្រាហ្វិក ឬអក្សរបោះពុម្ពដែលត្រូវភ្ជាប់បង្ហាញនៅលើសំបកវេចខ្ចប់ផលិតផល ឬដាក់តាំងបង្ហាញក្បែរផលិតផល ដើម្បីបញ្ជាក់នូវការធានាគុណភាពផលិតផល។

**ការផ្តល់វិញ្ញាបនបត្រ (Certification)៖**

សំដៅដល់នីតិវិធី ដែលប្រតិបត្តិករ ឬក្រុមប្រតិបត្តិករទទួលបាននូវការបញ្ជាក់ទទួលស្គាល់ជាលាយលក្ខណ៍អក្សរ និងទំនុកចិត្តពីអង្គភាព ឬស្ថាប័នផ្តល់វិញ្ញាបនបត្រដែលដំណើរការកំណត់អត្តសញ្ញាណយ៉ាងច្បាស់លាស់មួយ ត្រូវបានអនុវត្តតាមវិធីសាស្ត្រ ដើម្បីវាយតម្លៃថាប្រតិបត្តិករនោះ បានធ្វើការផលិត ផលិតផលណាមួយស្របទៅតាមវិធាន ឬតម្រូវការដាក់លាក់មួយ។

**ការលើកលែង (Exception)៖**

សំដៅដល់ការអនុញ្ញាត ដែលបានផ្តល់ឱ្យប្រតិបត្តិករដោយអាជ្ញាធរមានសមត្ថកិច្ច ឬអង្គការចេញវិញ្ញាបនបត្រ ដើម្បីលើកលែងពីការចាំបាច់នៃការអនុវត្តតាមវិធានកំណត់។ ការលើកលែងនេះត្រូវបានអនុញ្ញាតជូនដោយឈរលើមូលដ្ឋាននៃលក្ខណៈវិនិច្ឆ័យច្បាស់លាស់ ជាមួយយុត្តិកម្មច្បាស់លាស់ និងសម្រាប់រយៈពេលមានកំណត់មួយ។

**ក្រុមសារធាតុបង្កមហារីក (Carcinogen)៖**

សំដៅដល់សារធាតុសំយោគ ឬធម្មជាតិណាដែលអាចបង្ក ឬជំរុញឱ្យកើតជំងឺមហារីក។

**ខ្សែច្រវាក់ផ្គត់ផ្គង់ (Supply Chain)៖**

សំដៅដល់ប្រព័ន្ធមួយនៃរចនាសម្ព័ន្ធគ្រប់គ្រង មនុស្ស បច្ចេកវិទ្យា សកម្មភាព ព័ត៌មាន និងធនធាន ដែលត្រូវចូលរួមក្នុងការបញ្ជូនផលិតផល ឬសេវាមួយពីអ្នកផ្គត់ផ្គង់ទៅកាន់អតិថិជន និងអ្នកត្រូវការប្រើប្រាស់។

**គុណភាពសរីរាង្គ (Organic Quality) ៖**

សំដៅដល់ផលិតផល ឬការផលិតកែច្នៃ ដែលបានធ្វើឡើងដោយផ្អែកតាមវិធានកសិកម្មសរីរាង្គកម្ពុជា។

**ជីបៃតង/ជីស្រស់ (Green Manure)៖**

សំដៅដល់ដំណាំមួយប្រភេទដែលដាំដុះ ដើម្បីបង្កើតជាជីផ្តល់ទៅក្នុងដី ក្នុងគោលបំណងកែលម្អជីជាតិដី ទប់ស្កាត់ការហូរច្រោះដី ការបាត់បង់សារធាតុចិញ្ចឹម ការបំលែងប្រើប្រាស់ និងបង្កើនជីជាតិរុក្ខជាតិ និងការធ្វើឱ្យមានតុល្យភាពសារធាតុសរីរាង្គរបស់ដី។ ជីបៃតង/ជីស្រស់អាចរាប់បញ្ចូលទាំងដំណាំ រុក្ខជាតិ ឬស្មៅដែលដុះដោយឯកឯង។

**ជម្រក (Habitat)៖**

សំដៅដល់ទីកន្លែង ឬតំបន់ដែលប្រភេទរុក្ខជាតិ ឬសត្វដែលអាចរស់នៅ ឬលូតលាស់ទៅតាមធម្មជាតិ។ ជម្រកក៏ត្រូវបានប្រើប្រាស់ ដើម្បីសម្គាល់បណ្តាប្រភេទនៃជម្រក ដូចជាមហាសមុទ្រ ឆ្នេរសមុទ្រ មាត់ទន្លេ ដីព្រៃឈើ និងវាលស្មៅ។ល។

**មមោកបាតបឹង (Peat)៖**

សំដៅដល់សារធាតុរុក្ខជាតិពុកផុយដែលសម្បូរដោយជាតិកាបូន ហើយជាធម្មតាជាពពួកបាណកជាតិ និងច្រើនប្រទះឃើញនៅតំបន់សើមបាតបឹង ត្រពាំង ឬវាលភក់ដែលអាចប្រើប្រាស់ជាជី និងថាមពល។

**ជីវចម្រុះដី (Soil Biodiversity)៖**

សំដៅដល់ប្រភេទនៃមីក្រូសារពាង្គកាយ និងសារពាង្គកាយមានជីវិតទាំងអស់នៅក្នុងដីរួមបញ្ចូលទាំងសារពាង្គកាយមានប្រយោជន៍ និងសារពាង្គកាយបង្កហានិភ័យគ្រោះថ្នាក់។

**ជីសរីរាង្គ** ( Organic Fertilizer ) ៖

សំដៅដល់ប្រភេទជី ដែលមានប្រភពដើមពីផលិតផលរុក្ខជាតិឬសត្វ ( ជាពិសេសលាមកសត្វ ) ដែលឆ្លងកាត់ការបំបែកជាតុតាមរយៈដំណើរការជីវសាស្ត្រ ការធ្វើឱ្យមានសំណើម ការទុកឱ្យឡើងមេ ឬទុកឱ្យក្លាយជាកំប៉ុស្ត ឬដោយប្រើវិធីសាស្ត្រផ្សេងទៀត ដែលធ្វើឱ្យរូបធាតុដើមប្រែក្លាយដូចជាទម្រង់ជី ក្លាយជាកំប៉ុស្តសុទ្ធពេញលេញ ដោយគ្មានលាយសារធាតុគីមី គ្មានភ្នាក់ងារចម្លងជំងឺ និងរក្សានូវសារធាតុសរីរាង្គមិនតិចជាង ២០ភាគរយ ( Organic Matter «OM» ) និងអាចផ្តល់សារធាតុចិញ្ចឹមដល់រុក្ខជាតិនិងដំណាំ។

**ធាតុផ្សំ** ( Ingredient ) ៖

សំដៅដល់សារធាតុទាំងឡាយ រួមទាំងសារធាតុបន្ថែម ដែលប្រើប្រាស់ក្នុងការផលិត ឬការរៀបចំផលិតផល និងជាសមាសភាគនៃផលិតផលសម្រេច ទោះបីស្ថិតក្នុងទម្រង់កែច្នៃក្តី។

**តំបន់ការពារ** ( Buffer Zone ) ៖

សំដៅដល់តំបន់ ដែលខណ្ឌចែកព្រំប្រទល់រវាងទីតាំងផលិតកម្មកសិកម្មសរីរាង្គ និងតំបន់ផលិតកម្មកសិកម្មធម្មតា។

**តំបន់មានតម្លៃអភិរក្សខ្ពស់** ( High Conservation Value Areas ) ៖

សំដៅដល់តំបន់ ដែលត្រូវបានកំណត់ជាតំបន់មានសារសំខាន់ និងមានតម្លៃផ្នែកបរិស្ថាន វប្បធម៌ សេដ្ឋកិច្ចសង្គម ជីវចម្រុះ និងទេសភាព។

**និរន្តរភាព** ( Sustainable ) ៖

សំដៅដល់ការប្រើប្រាស់ធនធានក្នុងវិធីមួយ មិនហួសកម្រិតអតិបរមានៃលទ្ធភាពដែលវាអាចកកើតឡើងវិញបានឡើយ។

**ប្រតិបត្តិករ** ( Operator ) ៖

សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលអនុវត្តផលិតកម្មកែច្នៃធ្វើពាណិជ្ជកម្ម ឬគ្រប់គ្រងផលិតផលកសិកម្មសរីរាង្គនៅក្រោយពេលប្រមូលផល។

**ផលិតផលសារពាង្គកាយកែច្នៃសេ្បណេទិច** GMO ( Genetic Modification Organism ) ៖

សំដៅដល់ផលិតផលដំណាំដែលផលិត ឬមានប្រភពពីសារពាង្គកាយកែច្នៃស្បេណេទិច ដែលផ្ទុកនូវសារធាតុស្បេណេទិចថ្មី តាមរយៈការប្រើប្រាស់ជីវបច្ចេកវិទ្យាទំនើបបានន័យថា ជាផលិតផលដែលមានបម្រែបម្រួលសែនទាំងស្រុងឬមួយផ្នែក។

**ផលិតកម្មបែងចែក (Split Production)៖**

សំដៅដល់ផ្នែកខ្លះនៃកន្លែងដាំដុះ ឬកន្លែងកែច្នៃដែលគោរពតាមគោលការណ៍សរីរាង្គ។ ក្រៅពីនេះផ្នែកដែលនៅសល់អាចជាផ្នែកដែលមិនអនុវត្តសរីរាង្គ និងផ្នែកដែលស្ថិតក្នុងដំណាក់កាលផ្លាស់ប្ដូរជាសរីរាង្គ(សូមមើលផលិតកម្មស្រប)។

**ផលិតផលសរីរាង្គ (Organic Products)៖**

សំដៅដល់ផលិតផលដែលបានផលិត ឬកែច្នៃស្របតាមវិធានកសិកម្មសរីរាង្គសម្រាប់ប្រើប្រាស់ជាចំណីអាហារ ឬចំណីសត្វ។

**ផលិតកម្មស្រប (Parallel Production)៖**

សំដៅដល់ដំណើរការស្របគ្នានៃ ផលិតកម្មសរីរាង្គនិងផលិតកម្មដែលស្ថិតក្នុងដំណាក់កាលផ្លាស់ប្ដូរទៅជាផលិតកម្មសរីរាង្គ។

**ភាពចម្លង ឬលាយឡំជាតុកខ្វក់ (Contamination)៖**

សំដៅដល់ការប៉ះពាល់នៃដំណាំសរីរាង្គ សត្វ ដី ឬផលិតផលកសិកម្មសរីរាង្គជាមួយសារធាតុ និងសរីរាង្គដែលមានហានិភ័យចំពោះគុណភាពនិងសុវត្ថិភាពផលិតផលសរីរាង្គ។

**ភ្នាក់ងារគ្រប់គ្រងសមាសភាពចង្រៃតាមវិធានការជីវសាស្ត្រ (Biocontrol Agent)៖**

សំដៅដល់ពពួកមីក្រូសរីរាង្គ និងសារពាង្គកាយមានជីវិត និងមានប្រយោជន៍ ដែលប្រើប្រាស់នៅក្នុងវិធីសាស្ត្រគ្រប់គ្រងសមាសភាពចង្រៃ រួមមានពពួក ប្រេដាទ័រ ប៉ារ៉ាស៊ីត សត្វស៊ីស្មៅ ឬពពួកសត្រូវធម្មជាតិផ្សេងទៀត ព្រមទាំងមានការចូលរួមពីតួនាទីគ្រប់គ្រងរបស់មនុស្សផងដែរ។ សត្រូវក្នុងធម្មជាតិរបស់សត្វល្អិត ដែលគេស្គាល់ថាជាភ្នាក់ងារគ្រប់គ្រងសមាសភាពចង្រៃតាមវិធានការជីវសាស្ត្រមានដូចជា ប្រេដាទ័រ ប៉ារ៉ាស៊ីត និងភ្នាក់ងារបង្កជំងឺ។ ភ្នាក់ងារគ្រប់គ្រងតាមវិធានការជីវសាស្ត្រទៅលើជំងឺរុក្ខជាតិជានិច្ចកាល គឺសំដៅទៅលើអង្គបដិបក្ខ។ ភ្នាក់ងារគ្រប់គ្រងសមាសភាពចង្រៃតាមវិធានការជីវសាស្ត្រនៅលើស្មៅចង្រៃ រួមមានសត្វស៊ីស្មៅជាអាហារ និងភ្នាក់ងារបង្កជំងឺលើស្មៅចង្រៃទាំងនោះ។

**របាំង (Barrier)៖**

សំដៅដល់រនាំង ដែលរារាំងលំហូរនៃសារធាតុហាមឃាត់ពីតំបន់ជិតខាង មិនឱ្យឆ្លងចូល ឬឆ្លងកាត់តំបន់ផលិតកម្មកសិកម្មសរីរាង្គ។

**រយៈពេលផ្លាស់ប្តូរឬអន្តរកាល (Coversion Period)៖**

សំដៅដល់រយៈពេលរវាងការចាប់ផ្តើមនៃការអនុវត្តតាមវិធានកសិកម្មសរីរាង្គ និងការផ្តល់ឱ្យវិញ្ញាបនបត្របញ្ជាក់ជាផលិតផលសរីរាង្គស្រស់។

**លក្ខណៈប្រពៃណី (Traditional)៖**

សំដៅដល់ផលិតកម្ម ដែលផ្អែកលើចំណេះដឹងបច្ចេកទេសក្នុងស្រុកដែលត្រូវបានអនុវត្ត និងផ្ទេរពីមួយជំនាន់ទៅមួយជំនាន់ស្របទៅតាមលក្ខខណ្ឌសង្គមនិងបរិស្ថានក្នុងតំបន់។

**សរីរាង្គដាច់ខាត (Organic Integrity)៖**

សំដៅដល់កិច្ចប្រតិបត្តិកសិកម្ម ដែលអនុលោមទាំងស្រុងទៅនឹងគោលបំណងនៃវិធានកសិកម្មសរីរាង្គកម្ពុជា។

**សារធាតុដែលអាចបំបែកដោយជីវសាស្ត្រ (Biodegradable Input)៖**

សំដៅដល់ជីសរីរាង្គ ដែលផ្សំឡើងពីវត្ថុធាតុដើមធម្មជាតិមានលទ្ធភាពពុកផុយ ដោយសកម្មភាពរបស់បាក់តេរី ឬដំណើរការជីវសាស្ត្រដទៃទៀត រួមមានជីកំប៉ុស្តិ៍ ជីស្រស់ លាមកសត្វ និងកាកសំណល់សត្វ ឬរុក្ខជាតិ។

**សារធាតុបន្ថែមលើចំណីអាហារ (Food Additive)៖**

សំដៅដល់សារធាតុទាំងឡាយ ដែលជាធម្មតាមិនប្រើជាចំណីអាហារផ្ទាល់ ឬមិនប្រើប្រាស់ជាគ្រឿងផ្សំនៃអាហារនោះដែរ ទោះបីមានឬគ្មានតម្លៃជាសារធាតុចិញ្ចឹមក្តី ប៉ុន្តែគោលបំណងនៃការបន្ថែមលើចំណីអាហារគឺជាគោលដៅបច្ចេកវិទ្យាចំណីអាហារ (រួមបញ្ចូលទាំងរសជាតិ) នៅក្នុងផលិតកម្ម ការកែច្នៃ ការរៀបចំ ប្រព្រឹត្តិកម្ម ការវេចខ្ចប់ការដឹកជញ្ជូនឬការស្តុកទុកផលិតផលអាហារដែលផ្តល់ផលដោយផ្ទាល់ឬដោយប្រយោល និងប្រែក្លាយជាសមាសភាគមួយនៃចំណីអាហារនោះ ឬផ្តល់ចរិកលក្ខណៈពិសេសនៃអាហារនោះ។ អត្ថន័យខាងលើនេះមិនរាប់បញ្ចូល «សារធាតុពុល និងសារធាតុបន្ថែមដើម្បីថែរក្សាឬបង្កើនគុណភាពសារធាតុចិញ្ចឹម»ឡើយ។

**សារធាតុចិញ្ចឹមផ្តាច់ចេញ (Isolated Nutrients)៖**

សំដៅដល់ទម្រង់នីមួយៗដាច់ដោយឡែកពីគ្នានៃសារធាតុចិញ្ចឹម។

**សារធាតុជំនួយក្នុងការកែច្នៃ (Processing Aid)៖**

សំដៅដល់សារធាតុទាំងឡាយ ដោយមិនរាប់បញ្ចូលឧបករណ៍បរិក្ខារ និងមិនត្រូវបានប្រើប្រាស់ ជាគ្រឿងផ្សំក្នុងចំណីអាហារដោយផ្ទាល់ តែត្រូវបានប្រើប្រាស់ក្នុងគោលបំណងកែច្នៃវត្ថុធាតុដើមចំណីអាហារ ដើម្បីបំពេញគោលបំណងបច្ចេកទេសជាក់លាក់មួយ ហើយអាចបន្សល់ទុកនូវសំណល់ក្នុងផលិតផលសម្រេចដោយអចេតនាក្នុងលក្ខណៈមិនអាចជៀសវាងបាន។

**សារធាតុបន្ថែម (Additives)៖**

សំដៅដល់សារធាតុ ដែលបានដាក់បញ្ចូលទៅក្នុងផលិតផលកែច្នៃក្នុងគោលបំណងបច្ចេកទេស ដើម្បីបង្កើតជាសមាសភាពមួយរបស់ផលិតផលសម្រេច និងផ្តល់នូវលក្ខណៈផ្សេងៗនៃផលិតផលនេះ។

**ស្បេណទិចរុក្ខជាតិដើម (Plant Genetic Integrity)៖**

សំដៅដល់ការថែរក្សាពូជរុក្ខជាតិដើម្បីធានាថា ពូជរុក្ខជាតិទាំងនោះនៅតែរក្សាភាពសុទ្ធស្បេណទិចដូចលក្ខណៈដើម និងមិនលាយឡំដោយពូជផ្សេងទៀត។

**សារធាតុសំយោគ (Synthetic)៖**

សំដៅដល់សារធាតុមួយ ដែលត្រូវបានផលិតឡើងដោយដំណើរការគីមី ឬដោយដំណើរការមួយដែលមានការប្រើប្រាស់សារធាតុគីមី សម្រាប់ធ្វើការបំលែងសារធាតុដែលចំរាញ់ចេញពីរុក្ខជាតិធម្មជាតិ សត្វ ឬប្រភពធនធានរ៉ែ។ សារធាតុទាំងឡាយ ដែលកកើតដោយដំណើរការជីវសាស្ត្រ និងតាមធម្មជាតិមិនត្រូវបានចាត់ទុកជាសារធាតុសំយោគឡើយ។

**អំឡុងពេលផ្លាស់ប្តូរជាផលិតផលសរីរាង្គ (In-Conversion)៖**

សំដៅដល់រយៈពេលផ្លាស់ប្តូរជាផលិតផលសរីរាង្គ ដែលកំណត់លើស្លាកសញ្ញានៃផលិតផល ត្រូវផ្គត់ផ្គង់ចែកចាយលើទីផ្សារដោយបញ្ជាក់ថាផលិតផលស្រស់និងកែច្នៃនៃដំណាំដែលទទួលបានពីការផលិត ឬការកែច្នៃនោះ បានអនុលោមតាមវិធានកសិកម្មសរីរាង្គកម្ពុជា។

**អង្គភាពផ្តល់វិញ្ញាបនបត្រ (Certification Body)៖**

សំដៅដល់អគ្គនាយកដ្ឋានកសិកម្ម ឬនាយកដ្ឋានកសិ-ឧស្សាហកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលជាអ្នកទទួលខុសត្រូវលើការចេញវិញ្ញាបនបត្រជាផ្លូវការ ស្របតាមតួនាទី និងភារកិច្ចដូចមានចែងនៅក្នុងប្រការ៦ នៃប្រកាសស្តីពីវិធានកសិកម្មសរីរាង្គកម្ពុជា និងរូបសញ្ញាជាតិសម្រាប់អនុវត្តក្នុងផលិតកម្ម និងការកែច្នៃបឋមដំណាំស្បៀង។

តេរ៉ាតូហ្សែន (Teratogen)៖

សំដៅដល់មេរោគបង្ក ឬកត្តាបង្កជំងឺ ដែលបង្អាក់ការលូតលាស់ជាធម្មតារបស់អំប្រីយ៉ុង។

## ២. លក្ខខណ្ឌតម្រូវទូទៅ សម្រាប់ផលិតកម្មកសិកម្មសរីរាង្គ និងការកែច្នៃបឋម

### ២.១- ការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ី

គោលបំណង

ការអនុវត្តកសិកម្មសរីរាង្គប្រកបដោយនិរន្តរភាពជួយរក្សា ធ្វើឱ្យប្រសើរ និងបំពេញបាននូវវដ្តអេកូឡូស៊ីស្របតាមស្ថានភាពជាក់លាក់របស់ប្រព័ន្ធក្សេត្របរិស្ថាន និងស្ថានភាពភូមិសាស្ត្រនៃតំបន់ផលិតកម្មកសិកម្ម។

លក្ខខណ្ឌតម្រូវ

២.១.១-ត្រូវគ្រប់គ្រងតាមវិធានកសិកម្មសរីរាង្គដើម្បីជួយរក្សា និង/ឬ លើកកម្ពស់ជីវចម្រុះនៅក្នុងកសិដ្ឋាន និងលើផ្ទៃដីដាំដុះតាមរយៈការអនុវត្ត ការដាំដំណាំឆ្លាស់ ដំណាំបង្វិល ដំណាំច្រើនមុខ ការប្រើជីស្រស់ ការដាំដើមឈើជារបងរស់តាមព្រំដី ឬជារបាំងខ្យល់។

២.១.២-ត្រូវគ្រប់គ្រងតាមវិធានកសិកម្មសរីរាង្គដោយមិនធ្វើសកម្មភាពទាំងឡាយ ដែលបណ្តាលឱ្យមានផលប៉ះពាល់ជាអវិជ្ជមានណាមួយទៅដល់តំបន់ ដែលត្រូវបានទទួលស្គាល់ជាផ្លូវការថា ជាតំបន់អភិរក្សដ៏មានតម្លៃ និងតំបន់កេរដំណែល ដូចជាតំបន់ការពារសត្វព្រៃ តំបន់ដីសើម និងតំបន់ទីជំរាលជាដើម។

២.១.៣-ត្រូវធានាឱ្យមាននូវគ្រប់ដំណាក់កាលនៃខ្សែច្រវាក់ផលិតកម្ម ការទុកដាក់ ការកែច្នៃ និងការផ្គត់ផ្គង់ចែកចាយទាំងមូលនៅក្នុងប្រព័ន្ធកសិកម្មសរីរាង្គ។

### ២.២- ការគ្រប់គ្រងដី

គោលបំណង

ប្រព័ន្ធកសិកម្មសរីរាង្គជួយថែរក្សា កែលម្អ គុណភាពដី និងលើកកម្ពស់ការប្រើប្រាស់ដីប្រកបដោយប្រសិទ្ធភាពខ្ពស់។ រាល់ហានិភ័យ ដែលបង្កដល់ការបំពុលបរិស្ថាន ត្រូវបានកំណត់អត្តសញ្ញាណ និងកាត់បន្ថយឱ្យនៅតិចបំផុត។

**លក្ខខណ្ឌតម្រូវ**

២.២.១-ការគ្រប់គ្រងដី ត្រូវថែរក្សាឱ្យបាននូវសារធាតុសរីរាង្គលើដីនោះ ក្នុងគោលបំណងជួយ ឬបង្កើនបរិមាណសារធាតុមមោកនៅក្នុងដី។

២.២.២-ជីជាតិដី និងមុខងាររបស់មីក្រូសរីរាង្គ និងសារពាង្គកាយមានជីវិតក្នុងដីត្រូវរក្សាឱ្យមាន និងត្រូវបង្កើនតាមរយៈការដាំពពួកដំណាំសណ្តែកនិងរុក្ខជាតិផ្សេងទៀត ដើម្បីបង្កើតជាជីស្រស់។

២.២.៣-ប្រព័ន្ធផលិតកម្មដំណាំសរីរាង្គត្រូវអនុវត្តវិធីសាស្ត្រដាំដុះ ដែលរួមមានការប្រើប្រាស់ជីធម្មជាតិ និងធាតុចូលផ្សេងៗទៀតតាមរយៈការបំបែកធាតុរបស់ពពួកមីក្រូសរីរាង្គ ឬការដាំដំណាំដែលមានមុខងារស្រូបយកអាសូតពីបរិយាកាស ឱ្យទៅជាសារធាតុចិញ្ចឹមដែលដំណាំអាចស្រូបយកបាន។

២.២.៤-ការគ្រប់គ្រងជីជាតិដីត្រូវអនុវត្តនូវបណ្តាវិធាននានា ដែលជួយធ្វើឱ្យកកើតឡើងវិញនូវសារធាតុសរីរាង្គក្នុងប្រព័ន្ធផលិតកម្ម ដូចជាការប្រើជីស្រស់ និងជីកំប៉ុស្តជាដើម។

២.២.៥-ការរៀបចំ និងការសម្អាតដីដោយការដុតដើមរុក្ខជាតិត្រូវបានហាមឃាត់ លើកលែងតែដីនោះជាផ្នែកមួយនៃការអនុវត្តតាមបែបប្រពៃណីនិងគ្រប់គ្រងបានល្អ។ ការដាំដំណាំតាមបែបកសិកម្មពនេចរដោយការដុត ឬការកាប់ពន ត្រូវតែកាត់បន្ថយជាបណ្តើរៗ។

២.២.៦-ប្រព័ន្ធផលិតកម្មដំណាំសរីរាង្គ ត្រូវអនុវត្តវិធានការទប់ស្កាត់ការធ្លាក់ចុះគុណភាពដី ដូចជាការហូរច្រោះ ការជ្រាបចូលទឹកប្រៃ និងហានិភ័យពាក់ព័ន្ធផ្សេងៗទៀត។

## ២.៣- ការគ្រប់គ្រងទឹក

**គោលបំណង**

ប្រព័ន្ធកសិកម្មសរីរាង្គជួយថែរក្សា ធ្វើឱ្យប្រសើរឡើង និងរក្សាបាននូវគុណភាពទឹកទាំងទឹកក្រោមដី និងទឹកលើដី និងការប្រើប្រាស់ទឹកប្រកបដោយប្រសិទ្ធភាព។ ហានិភ័យនានាដែលបង្កការបំពុលបរិស្ថានត្រូវបានកំណត់អត្តសញ្ញាណ និងកាត់បន្ថយឱ្យបានជាអតិបរមា។

**លក្ខខណ្ឌតម្រូវ**

២.៣.១-ការគ្រប់គ្រងតាមវិធានសរីរាង្គត្រូវធានាឱ្យបានថា ធនធានទឹកបានប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពឆ្លើយតបទៅនឹងយុទ្ធសាស្ត្រប្រើប្រាស់ទឹកសមស្រប ជៀសវាងការប្រើប្រាស់ខ្ជះខ្ជាយនិងបង្កឱ្យមានភាពកខ្វក់។

២.៣.២-ការគ្រប់គ្រងតាមវិធានសរីរាង្គត្រូវបង្ការការបំពុលបរិស្ថាន និងត្រូវថែរក្សាគុណភាពទឹក។



Nyks Thai

## ២.៤- ការជៀសវាងភាពចម្លង និងការលាយឡំជាតុកខ្វក់

### គោលបំណង

ការគ្រប់គ្រងតាមវិធានសរីរាង្គ កម្រិតកំណត់ការប្រើប្រាស់ធាតុចូលសំយោគនៅគ្រប់ដំណាក់កាលផលិតកម្ម និងខ្សែច្រវាក់ផ្គត់ផ្គង់ ដើម្បីរក្សាសុវត្ថិភាពរបស់មនុស្សនិងបរិស្ថានពីការបង្កហានិភ័យ ដោយសារសារធាតុគីមីគ្រោះថ្នាក់។ ការអនុវត្តន៍ខាងលើ អាចកាត់បន្ថយជាអតិបរមានូវការបំពុល និងការខូចខាតក្នុងផលិតកម្ម ឬកន្លែងកែច្នៃនិងបរិស្ថានជុំវិញ។

### លក្ខខណ្ឌតម្រូវ

២.៤.១-ការគ្រប់គ្រងតាមវិធានសរីរាង្គ ត្រូវមានវិធានការបង្ការភាពចម្លង ឬការលាយឡំសារធាតុគីមី ដែលអាចមានឥទ្ធិពលអាក្រក់ដល់ភាពសុទ្ធនៃសរីរាង្គនៅក្នុងខ្សែច្រវាក់ផ្គត់ផ្គង់។ វិធានការបង្ការនេះអាច រួមមានការរៀបចំឱ្យមានជារបាំង ឬតំបន់ការពារ ផលិតកម្ម ការលាងសម្អាតសម្ភារឧបករណ៍កសិដ្ឋាន ទីកន្លែង និងសម្ភារបរិក្ខារកែច្នៃ។

២.៤.២-ការគ្រប់គ្រងតាមវិធានសរីរាង្គ ត្រូវខិតខំកំណត់រកឱ្យឃើញនូវប្រភពនៃភាពចម្លង និងភាពលាយឡំជាតុកខ្វក់ដើម្បីលុបបំបាត់។

២.៤.៣-ប្រព័ន្ធគ្រប់គ្រងតាមវិធានសរីរាង្គ មិនត្រូវប្រើផលិតផលសារពាង្គកាយកែច្នៃស្បៀហ្សណេទិច (GMO) នៅគ្រប់ដំណាក់កាលទាំងអស់នៃផលិតកម្ម និងការកែច្នៃ។

២.៤.៤-ប្រព័ន្ធគ្រប់គ្រងតាមវិធានសរីរាង្គ មិនត្រូវប្រើប្រាស់គម្របឬកំទេចកំទីដែលមិនអាចបំបែង ដោយពពួកមីក្រូសរីរាង្គ។

## ២.៥- ផលិតផលប្រមូលពីរុក្ខជាតិព្រៃ និងការគ្រប់គ្រងដីសាធារណៈ និងដីសម្បហភាព

### គោលបំណង

ការប្រមូលផលពីរុក្ខជាតិព្រៃ នៅលើដីព្រៃ ឬដីសម្បហភាព ត្រូវអនុវត្តប្រកបដោយនិរន្តរភាពដោយមិនប្រើធាតុចូល ឬបច្ចេកទេសហាមឃាត់ ដែលផ្ទុយទៅនឹងវិធានកសិកម្មសរីរាង្គ។

### លក្ខខណ្ឌតម្រូវ

២.៥.១-ការគ្រប់គ្រងការប្រមូលផលរុក្ខជាតិព្រៃ ត្រូវធានានិរន្តរភាពនៃទិន្នផលជៀសវាងការគំរាមកំហែងចំពោះប្រព័ន្ធអេកូឡូស៊ីនៅនឹងកន្លែង។

២.៥.២-ការប្រមូលផលរុក្ខជាតិព្រៃ ត្រូវធ្វើតែលើដីព្រៃប្រមូលផលដែលមានដែនកំណត់ច្បាស់លាស់។



Nyes ᵀᴴ

២.៥.៣-ការគ្រប់គ្រងការប្រមូលផលរុក្ខជាតិព្រៃ មិនត្រូវអនុវត្តទៅលើរុក្ខជាតិ ដែលទទួលបានការការពារ និងជិតផុតពូជ។

២.៥.៤-ដីប្រមូលផលរុក្ខជាតិព្រៃ ត្រូវស្ថិតនៅចម្ងាយសមស្របពីផ្ទៃដីដាំដុះតាមប្រពៃណី ផ្ទៃដីដែលមានការបំពុល និងពីប្រភពងាយចម្លងផ្សេងទៀត ដែលធ្វើឱ្យបាត់បង់ លក្ខណៈសរីរាង្គ។

## ២.៦- តម្រូវការនៃការផ្លាស់ប្តូរ

### គោលបំណង

ការផ្លាស់ប្តូរទៅជាផលិតកម្មសរីរាង្គទាមទារឱ្យមានរយៈពេលអន្តរកាលមួយ សម្រាប់កែប្រែគុណភាពនិងសុខភាពដី និងប្រព័ន្ធអេកូឡូស៊ីបានប្រសើរឡើង ហើយកាត់បន្ថយបាននូវកាកសំណល់សារធាតុគីមីពុលក្នុងដី។

### លក្ខខណ្ឌតម្រូវ

២.៦.១-ការផ្លាស់ប្តូរទៅជាផលិតកម្មសរីរាង្គ ត្រូវការរយៈពេលគ្រប់គ្រងតាមវិធានសរីរាង្គយ៉ាងតិច១២ខែ សម្រាប់ដំណាំប្រចាំរដូវ និងយ៉ាងតិច១៨ខែ សម្រាប់ដំណាំអចិន្ត្រៃយ៍។ រយៈពេលផ្លាស់ប្តូរអាចត្រូវបានពន្យារដោយផ្អែកទៅលើការរកឃើញ និងការវាយតម្លៃទៅលើបញ្ហាពាក់ព័ន្ធ និងហានិភ័យផ្សេងៗ ដែលអាចកើតមានឡើងការលើកលែងចំពោះលក្ខខណ្ឌតម្រូវនេះអាចធ្វើបានតែក្នុងករណីការអនុវត្តន៍បច្ចេកទេសដាំដុះតាមប្រពៃណីមិនបានប្រើប្រាស់ធាតុចូលកសិកម្ម ឬអនុវត្តសកម្មភាពដែលផ្ទុយនឹងវិធានកសិកម្មសរីរាង្គ។

២.៦.២-ការចាប់ផ្តើមរយៈពេលផ្លាស់ប្តូរ នឹងត្រូវគិតចាប់ពីកាលបរិច្ឆេទនៃការចាប់ផ្តើមរៀបចំឯកសារគ្រប់គ្រងតាមវិធានសរីរាង្គ។

២.៦.៣-ផ្ទៃដីដែលផ្លាស់ប្តូរ មិនអាចអនុវត្តបច្ចេកទេសដាំដុះតាមទំលាប់ចាស់បានឡើយ។

## ២.៧- ផលិតកម្មបែងចែក និងផលិតកម្មស្រប

### គោលបំណង

ក្នុងផ្ទៃកម្មួយនៃកសិដ្ឋានសរីរាង្គជាក់លាក់ មិនអនុញ្ញាតឱ្យមានសកម្មភាព និងការគ្រប់គ្រងតាមបែបសរីរាង្គផង និងមិនសរីរាង្គផងនោះទេ។

### លក្ខខណ្ឌតម្រូវ

ការគ្រប់គ្រងតាមវិធានសរីរាង្គ ត្រូវបែងចែកឱ្យច្បាស់លាស់នូវខ្សែប្រវាក់ផលិតកម្ម និង

ការផ្គត់ផ្គង់រវាងផ្នែកសរីរាង្គ និងអសរីរាង្គ។ ខ្សែច្រវាក់ផលិតកម្មនិងការផ្គត់ផ្គង់ នៅក្នុងផលិតកម្មស្របត្រូវញែកឱ្យដាច់ពីគ្នារវាងផលិតកម្មសរីរាង្គ និងផលិតកម្មក្នុងដំណាក់កាលផ្លាស់ប្តូរទៅជាផលិតកម្មសរីរាង្គ តាមរយៈការរៀបចំរបាំងរូបសាស្ត្រផ្សេងៗ ការគ្រប់គ្រងការអនុវត្តន៍ ដូចជាការដាំដុះពូជខុសគ្នា ឬពេលវេលាប្រមូលផលខុសគ្នា ការទុកដាក់ធាតុចូល និងផលិតផលជាដើម។

## ២.៨- ការរក្សាការគ្រប់គ្រងតាមវិធានកសិកម្មសរីរាង្គ

### គោលបំណង

ប្រព័ន្ធផលិតកម្មតាមវិធានកសិកម្មសរីរាង្គ ត្រូវប្រកាន់ខ្ជាប់ការប្រើប្រាស់វិធីសាស្ត្រផលិតកម្មតាមវិធានកសិកម្មសរីរាង្គ។

### លក្ខខណ្ឌតម្រូវ

ការគ្រប់គ្រងតាមវិធានកសិកម្មសរីរាង្គ មិនអាចធ្វើការផ្លាស់ប្តូរចុះឡើងរវាងការគ្រប់គ្រងតាមវិធានកសិកម្មសរីរាង្គ និងតាមទំលាប់ចាស់។ ក្នុងករណីធ្វើការផ្លាស់ប្តូរ ផ្ទៃដីកសិកម្មសរីរាង្គពីមុនត្រូវអនុវត្តឡើងវិញនូវវិធានសរីរាង្គ។

# ៣. ប្រព័ន្ធគ្រប់គ្រងផលិតកម្មកសិកម្មសរីរាង្គ

## ៣.១- ការជ្រើសរើសដំណាំ និងពូជដំណាំ

### គោលបំណង

ដំណាំ និងពូជត្រូវដាំដុះឱ្យស្របទៅនឹងលក្ខខណ្ឌក្នុងស្រុក ហើយភាពសុទ្ធនៃដំណាំសរីរាង្គត្រូវរក្សាឱ្យមាននៅក្នុងផលិតកម្ម។

### លក្ខខណ្ឌតម្រូវ

៣.១.១-អ្នកផលិត ត្រូវបានលើកទឹកចិត្តឱ្យរក្សាទុកលក្ខណៈតំណពូជសុទ្ធរបស់ពូជដំណាំដែលសមស្របទៅនឹងលក្ខខណ្ឌក្សេត្របរិស្ថានក្នុងស្រុក។ ឧទាហរណ៍ការលើកទឹកចិត្តឱ្យប្រើប្រាស់ពូជមានប្រភព ឬមានដើមកំណើតនៅក្នុងស្រុក ប៉ុន្តែហាមឃាត់ចំពោះការប្រើប្រាស់ពូជផលិតផលសារពាង្គកាយកែច្នៃស្បេណេទិច(GMO)។

៣.១.២-ក្នុងផលិតកម្មដំណាំសរីរាង្គ ត្រូវប្រើគ្រាប់ពូជ និងបំណែកពូជដំណាំ ដែលមានគុណភាពសរីរាង្គ លើកលែងតែគ្រាប់ពូជ និងបំណែកពូជទាំងនោះមិនអាចរកបាន និងទទួលបានការអនុញ្ញាតពីអង្គភាពជំនាញ។ ក្នុងផលិតកម្មដំណាំសរីរាង្គ អាចប្រើគ្រាប់ពូជ និងបំណែកពូជដំណាំ OPV ដោយមិនមានប្រព្រឹត្តិកម្មគីមី។ ចំពោះ ពូជអ៊ីប្រ៊ីដ អាចប្រើប្រាស់បានលុះត្រាមានការអនុញ្ញាតពីមន្ត្រីជំនាញជាមុនសិន។

៣.១.៣-ប្រព័ន្ធផលិតកម្មដំណាំសរីរាង្គ ត្រូវប្រើគ្រាប់ពូជ និងបំណែកពូជដំណាំដែលពុំមានគ្រាំ/ប្រលាក់ថ្នាំគីមី។ ប្រសិនបើមានគ្រាំ/ប្រលាក់ថ្នាំគីមីគឺអនុញ្ញាតឱ្យគ្រាំ ឬប្រលាក់ជាមួយសារធាតុដែលមានចែងនៅក្នុងតារាងទី២។ ក្នុងស្ថានភាពបែបនេះ ត្រូវលាងសារធាតុគីមីហាមឃាត់ ដែលបានគ្រាំ ឬប្រលាក់ចេញពីគ្រាប់ពូជ ឬបំណែកពូជដំណាំមុនពេលប្រើ។

## ៣.២- ពិពិធកម្មនៅក្នុងផលិតកម្មដំណាំ

### គោលបំណង

ការជ្រើសរើសប្រភេទដំណាំ និងពូជដំណាំត្រូវផ្អែកទៅលើភាពបន្សុំទៅនឹងលក្ខខណ្ឌក្បេត្របរិស្ថានក្នុងស្រុកអាកាសធាតុ សត្វល្អិត ជំងឺ។

### លក្ខខណ្ឌតម្រូវ

៣.២.១-ផលិតកម្មដំណាំសរីរាង្គត្រូវប្រើប្រាស់វិធីសាស្ត្រដាំដុះដំណាំចម្រុះ ដែលជាផ្នែកមួយមិនអាចខ្វះបាននៅក្នុងប្រព័ន្ធគ្រប់គ្រងកសិដ្ឋាន។ ចំពោះដំណាំអចិន្ត្រៃយ៍ រួមមានការប្រើប្រាស់រុក្ខជាតិគម្របដី។ ចំពោះដំណាំប្រចាំឆ្នាំ រួមមានការប្រើវិធីសាស្ត្រដាំដុះដំណាំឆ្លាស់ ការដាំដំណាំបង្វិល ដំណាំគម្របដី (ជីស្រស់) ការដាំដុះដំណាំចន្លោះ ឬការដាំដំណាំច្រើនមុខដែលផ្តល់លទ្ធផលអាចធ្វើការប្រៀបធៀបបាន។

៣.២.២-ប្រព័ន្ធផលិតកម្មដំណាំសរីរាង្គត្រូវដាំដុះដោយពឹងផ្អែកនៅលើដីជាមូលដ្ឋាន ។

## ៣.៣- ជីជាតិដី និងការដាក់ជី

### គោលបំណង

ការគ្រប់គ្រងជីជាតិដី ជួយបង្កើនសារធាតុចិញ្ចឹមដល់ដំណាំតាមរយៈប្រព័ន្ធអេកូឡូស៊ីដី និងធ្វើឱ្យមានតុល្យភាពនៃសារធាតុចិញ្ចឹមនៅក្នុងដី។

### លក្ខខណ្ឌតម្រូវ

៣.៣.១-ការគ្រប់គ្រងជីជាតិដីតាមវិធានកសិកម្មសរីរាង្គ អនុញ្ញាតឱ្យប្រើបានតែជី និងសារធាតុរ៉ែដែលមានក្នុងធម្មជាតិ ដោយជួយបំពេញបន្ថែមពីលើវិធីសាស្ត្រប្រើប្រាស់ជីតាមគោលការណ៍ជីវសាស្ត្ររួមមាន ការផ្សំជាមួយជីស្រស់ និងជីកំប៉ុស្តជាដើម។

៣.៣.២-ការគ្រប់គ្រងជីជាតិដីតាមវិធានកសិកម្មសរីរាង្គអនុញ្ញាតឱ្យប្រើជីកំប៉ុស្ត ពពួកមីក្រូសរីរាង្គមានប្រយោជន៍ និងធាតុផ្សំមានប្រភពពីរុក្ខជាតិ។ ធាតុផ្សំជីវសកម្មពីម្សៅថ្មដែលមានសារធាតុរ៉ែ លាមកសត្វ ឬរុក្ខជាតិផ្សេងៗក៏អាចប្រើដើម្បីបង្កើនជីជាតិដី និងសកម្មភាព

ជីវសាស្ត្ររបស់ដីបានដែរ។ ការគ្រប់គ្រងជីជាតិដីតាមវិធានកសិកម្មសរីរាង្គអនុញ្ញាតឱ្យប្រើបានតែសារធាតុបង្កើនជីជាតិដី ដែលមានរាយឈ្មោះនៅក្នុងតារាងទី១នៃឧបសម្ព័ន្ធទី១ ស្ដីពីវិធានកសិកម្មសរីរាង្គកម្ពុជានេះប៉ុណ្ណោះ។

៣.៣.៣-ការគ្រប់គ្រងជីជាតិដីតាមវិធានកសិកម្មសរីរាង្គមិនអនុញ្ញាតឱ្យប្រើនូវ ជីគីមី និងជីដែលធ្វើឱ្យរលាយតាមវិធីសាស្ត្រគីមី ឧទាហរណ៍ ជីអ៊ុយរ៉េ និង ជីស៊ុបពែផូស្វាតជាដើម។

៣.៣.៤-ការគ្រប់គ្រងជីជាតិដីតាមវិធានកសិកម្មសរីរាង្គ គឺមិនអនុញ្ញាតឱ្យប្រើកាកសំណល់របស់មនុស្ស (លាមក ទឹកម៉ូត្រ សំណល់ពីបង្គន់ ។ល។) ធ្វើជាជីទៅលើគ្រប់មុខដំណាំសរីរាង្គទាំងអស់។

## ៣.៤- ការគ្រប់គ្រងការលូតលាស់ ជំងឺ ស្មៅ និងសត្វល្អិតចង្រៃ

### គោលបំណង

ប្រព័ន្ធគ្រប់គ្រងផលិតកម្មដំណាំសរីរាង្គ ចូលរួមចំណែកលើកកម្ពស់ និងធានាឱ្យដំណាំមានសុខភាពល្អ ព្រមទាំងរក្សានូវផលិតភាព និងភាពដើមនៃក្សេត្របរិស្ថាន។

### លក្ខខណ្ឌតម្រូវ

៣.៤.១-ការគ្រប់គ្រងផលិតកម្មដំណាំសរីរាង្គត្រូវផ្អែកលើដំណើរការ និងយន្តការជាវិជ្ជមាននៃអន្តរអំពើទៅវិញទៅមក ដើម្បីគ្រប់គ្រប់ការលូតលាស់ជំងឺ ស្មៅ និងសត្វល្អិតចង្រៃ។ ដំណើរការ និងយន្តការទាំងនេះរួមមានការគ្រប់គ្រងដីដែលបន្សាំទៅនឹងដំណាំ និងទីកន្លែងដាំដុះ ការភ្ជួររាស់ដី ការដាំដុះដំណាំ ការជ្រើសរើសពូជសមស្រប ការជំរុញមុខងារជីវចម្រុះដូចជាការប្រើប្រាស់ភ្នាក់ងារកំចាត់ជីវសាស្ត្រជាដើម។ ក្នុងករណីដែលមានការប្រើប្រាស់វិធានការបន្ថែម អាចអនុញ្ញាតឱ្យប្រើប្រាស់វិធីសាស្ត្រគ្រប់គ្រងសមាសភាពចង្រៃដោយប្រើកំដៅ និងប្រើប្រាស់ភ្នាក់ងារការពារដំណាំ និងសារធាតុជំរុញការលូតលាស់។

៣.៤.២-ផលិតកម្មដំណាំសរីរាង្គ ត្រូវប្រើសារធាតុសកម្មសម្រាប់គ្រប់គ្រងការលូតលាស់ជំងឺ ស្មៅ និងសត្វល្អិតចង្រៃ និងការលូតលាស់ដំណាំដូចមានរាយឈ្មោះក្នុងតារាងទី២ នៃឧបសម្ព័ន្ធទី១ស្ដីពីវិធានកសិកម្មសរីរាង្គកម្ពុជា។

៣.៤.៣-ផលិតកម្មដំណាំសរីរាង្គត្រូវធានាថា សារធាតុផ្សំ ឬសារធាតុសកម្ម ដែលប្រើក្នុងផលិតកម្មដំណាំមិនមែនជាសារធាតុបង្កជំងឺមហារីក និងមិនធ្វើឱ្យមានបម្រែបម្រួលស្បេណោទិច ហើយក៏មិនបង្កឱ្យរលូតកូន ឬបំផ្លាញប្រព័ន្ធប្រសាទឡើយ។

## ៣.៥- ការគ្រប់គ្រងក្រោយពេលប្រមូលផល

**គោលបំណង**

ការគ្រប់គ្រងក្រោយពេលប្រមូលផលនៅក្នុងកសិដ្ឋាន ត្រូវរក្សាបាននូវលក្ខណៈសរីរាង្គដាច់ខាតរបស់ផលិតផលសរីរាង្គ។

**លក្ខខណ្ឌតម្រូវ**

ការគ្រប់គ្រងក្រោយពេលប្រមូលផលនៅក្នុងកសិដ្ឋាន ត្រូវចាត់វិធានការបង្ការភាពចម្លង ឬលាយឡំជាតុកខ្វក់ និងការលាយឡំគ្នារវាងផលិតផលសរីរាង្គ និងផលិតផលមិនមែនសរីរាង្គ នៅក្នុងពេលកែច្នៃ (ការបោកបែន ការបេកសំបក ការយកសំបកចេញ ការសម្អាត ការដាក់ឱ្យត្រជាក់ ការកាត់ជាកង់ៗ និងការសម្ងួត) វេចខ្ចប់ ទុកដាក់ និងដឹកជញ្ជូន។

## ៤. ខ្សែច្រវាក់នៃការកែច្នៃ

### ៤.១- លក្ខខណ្ឌទូទៅ

**គោលបំណង**

ប្រព័ន្ធគ្រប់គ្រងការកែច្នៃ ត្រូវរក្សាបានលក្ខណៈសរីរាង្គដាច់ខាតរបស់ផលិតផលសរីរាង្គ។

**លក្ខខណ្ឌតម្រូវ**

៤.១.១-ការគ្រប់គ្រងការកែច្នៃសរីរាង្គ គឺត្រូវអនុវត្តនូវវិធានការបង្ការភាពចម្លងមេរោគ ឬលាយឡំជាតុកខ្វក់ និងការលាយចូលគ្នារវាងផលិតផលសរីរាង្គ និងផលិតផលមិនមែនសរីរាង្គ នៅពេលកែច្នៃ វេចខ្ចប់ ទុកដាក់ និងដឹកជញ្ជូន។

៤.១.២-ការគ្រប់គ្រងការកែច្នៃសរីរាង្គ ត្រូវអនុវត្តតាមគោលការណ៍អនុវត្តអនាម័យល្អ និងផលិតកម្មល្អ។

### ៤.២- ធាតុផ្សំ

**គោលបំណង**

ផលិតផលកែច្នៃតាមវិធានកសិកម្មសរីរាង្គ បានមកពីជាតុផ្សំសរីរាង្គ។

**លក្ខខណ្ឌតម្រូវ**

៤.២.១-ការកែច្នៃសរីរាង្គ អាចប្រើបានតែជាតុផ្សំសរីរាង្គប៉ុណ្ណោះ លើកលែងតែនៅពេលមិនអាចរកបាន ប៉ុន្តែត្រូវគោរពតាមវិធានដូចមានចែងក្នុងចំណុចទី៧។ ជាតុផ្សំដូចគ្នានៅក្នុងផលិតផលមួយ មិនត្រូវមានប្រភពពីសរីរាង្គ និងអសរីរាង្គផង។

៤.២.២-ការកែច្នៃសរីរាង្គប្រើបានតែសារធាតុរ៉ែ (រួមបញ្ចូលទាំងសារធាតុចិញ្ចឹមបន្ទាប់បន្សំផងដែរ) វីតាមីន សារធាតុខ្លាញ់ អាមីណូអាស៊ីត និងសារធាតុចិញ្ចឹមទោលផ្សេងទៀត ស្របតាមការតម្រូវផ្នែកច្បាប់ ឬការចង្អុលបង្ហាញជាក់លាក់ពីស្ថាប័នមានសមត្ថកិច្ច ជាពិសេសចំពោះផលិតផលចំណីអាហារ។

## ៤.៣- វិធីសាស្ត្រកែច្នៃ

### គោលបំណង

ចំណីអាហារសរីរាង្គ ត្រូវបានឆ្លងកាត់ការកែច្នៃតាមរយៈបច្ចេកទេសកែច្នៃរូបសាស្ត្រមេកានិច ឬជីវសាស្ត្រ។

### លក្ខខណ្ឌតម្រូវ

៤.៣.១-នៅក្នុងផលិតកម្មចំណីអាហារ ការកែច្នៃសរីរាង្គអនុញ្ញាតឱ្យប្រើតែវិធីសាស្ត្រកែច្នៃដែលមានលក្ខណៈជីវសាស្ត្រ រូបសាស្ត្រ មេកានិច ដែលមាននៅក្នុងធម្មជាតិប៉ុណ្ណោះ ដូចជាបកសំបក កិន បុក សង្កត់ និងការច្របាច់យកទឹកចេញជាដើម។

៤.៣.២-ការកែច្នៃសរីរាង្គ អនុញ្ញាតឱ្យប្រើតែសារធាតុបន្ថែម សារធាតុជំនួយក្នុងការកែច្នៃ សារធាតុសម្រាប់បំលែង និងសារធាតុសម្រាប់ចម្រាញ់។ សារធាតុទាំងនោះ សុទ្ធតែជាសារធាតុសរីរាង្គដូចមានចែងនៅក្នុងតារាងទី៣ នៃវិធានកសិកម្មសរីរាង្គកម្ពុជានេះ។

៤.៣.៣-ការកែច្នៃសរីរាង្គ មិនអនុញ្ញាតឱ្យប្រើបច្ចេកវិទ្យាបាញ់កាំរស្មី (កាំរស្មីអ៊ីយ៉ុង)។

៤.៣.៤-ការកែច្នៃសរីរាង្គ មិនត្រូវឱ្យមានប្រតិកម្មគីមីកើតឡើង ឬធ្វើឱ្យមានបម្រែបម្រួលដល់ម៉ូលេគុលផលិតផលសរីរាង្គឡើយ។

## ៤.៤- ការគ្រប់គ្រងជំងឺ និងសមាសភាពចង្រៃ

### គោលបំណង

ការការពារផលិតផលសរីរាង្គពីការបំផ្លាញរបស់សមាសភាពចង្រៃ និងជំងឺក្នុងអំឡុងពេលកែច្នៃ និងទុកដាក់ត្រូវអនុវត្តតាមវិធានកសិកម្មសរីរាង្គ ដោយមិនត្រូវធ្វើឱ្យបាត់បង់នូវលក្ខណៈសរីរាង្គជាច់ខាតរបស់ផលិតផលនោះឡើយ។

### លក្ខខណ្ឌតម្រូវ

៤.៤.១-ការគ្រប់គ្រងសមាសភាពចង្រៃក្នុងប្រព័ន្ធគ្រប់គ្រងការកែច្នៃផលិតផលសរីរាង្គត្រូវចាប់ផ្តើមដោយការបង្ការជាមុន ដូចជាការលុបបំបាត់ជម្រកសមាសភាពចង្រៃ និងការប្រើប្រាស់នូវមធ្យោបាយផ្សេងៗ ដែលនឹងចាត់ទុកជាមធ្យោបាយចម្បងក្នុងការគ្រប់គ្រងសមាសភាពចង្រៃ។

៤.៤.២-ក្នុងករណីប្រើវិធីសាស្ត្របង្ការមិនគ្រប់គ្រាន់ ជម្រើសដំបូងត្រូវប្រើប្រាស់វិធីសាស្ត្រជីវសាស្ត្រ មេកានិច រូបសាស្ត្រ និងសារធាតុដែលមានចែងនៅក្នុងតារាងទី៤ នៃវិធានកសិកម្មសរីរាង្គកម្ពុជានេះ ឧទាហរណ៍ ការគ្រប់គ្រងជំងឺ និងសមាសភាពចង្រៃមួយចំនួនតាមរយៈការប្រើភ្នាក់ងារជីវសាស្ត្រ ការបំពងសម្លេង ការបញ្ជូនរលកសម្លេង ការដាក់អន្ទាក់ពន្លឺ ឬអន្ទាក់ហ្វេរ៉ូម៉ូន ការគ្រប់គ្រងសីតុណ្ហភាព និងការគ្រប់គ្រងបរិយាកាសជាដើម។

៤.៤.៣-ក្នុងករណីប្រើប្រាស់វិធីសាស្ត្រផ្សេងទៀតក្រៅពីវិធីសាស្ត្រជីវសាស្ត្រ មេកានិច និងរូបសាស្ត្រខាងលើ ចាំបាច់ត្រូវស្នើសុំការអនុញ្ញាតពីស្ថាប័នពាក់ព័ន្ធ។

## ៤.៥- ការវេចខ្ចប់

### គោលបំណង

សម្ភារបរិក្ខារវេចខ្ចប់ ទុកដាក់ ឬដឹកជញ្ជូនមិនត្រូវចម្លងមេរោគ ឬលាយឡំជាតុកខ្វក់ឡើយ។

### លក្ខខណ្ឌតម្រូវ

៤.៥.១-សម្ភារបរិក្ខារវេចខ្ចប់ ទុកដាក់ ឬដឹកជញ្ជូនមិនត្រូវចម្លងមេរោគ ឬលាយឡំជាតុកខ្វក់ឡើយ។ ឧទាហរណ៍ សម្ភារវេចខ្ចប់ឬទុកដាក់ ដែលមានដាក់ថ្នាំការពារផ្សិត សារជាតុសម្រាប់រក្សាទុកបានយូរ ឬសារជាតុសម្រាប់ធ្វើធូបទកម្ម។ ថង់ ឬធុងដាក់ទំនិញផ្សេងៗ ដែលបានប្រើរួចមិនត្រូវយកមកប្រើឡើងវិញឡើយ។

៤.៥.២-លើកទឹកចិត្តឱ្យប្រើសម្ភារសម្រាប់វេចខ្ចប់ធ្វើពីវត្ថុជាតុ ឬសារជាតុណា ដែលអាចរលាយតាមលក្ខណៈជីវសាស្ត្របាន។

## ៤.៦- ការសម្អាត ការធ្វើអនាម័យ និងការការពារមិនឱ្យឆ្លងមេរោគនៅលើសម្ភារកែច្នៃចំណីអាហារ

### គោលបំណង

ការសម្អាត ការធ្វើអនាម័យ និងការការពារមិនឱ្យឆ្លងមេរោគនៅលើសម្ភារកែច្នៃចំណីអាហារមិនត្រូវអនុវត្តឱ្យឆ្លងមេរោគ ឬលាយឡំជាតុកខ្វក់ដល់ផលិតផលសរីរាង្គឡើយ។

### លក្ខខណ្ឌតម្រូវ

៤.៦.១-ការគ្រប់គ្រងតាមវិធានកសិកម្មសរីរាង្គ អនុញ្ញាតឱ្យប្រើប្រព័ន្ធសម្រាប់លាងសម្អាត និងការពារមិនឱ្យឆ្លងមេរោគទៅលើឧបករណ៍សម្ភារបរិក្ខាកែច្នៃដែលមិនឆ្លងមេរោគ ឬលាយឡំជាតុកខ្វក់ដល់ផលិតផលសរីរាង្គឡើយ។

៤.៦.២-ការការពារមិនឱ្យឆ្លងមេរោគ ដែលអាចប៉ះពាល់ជាមួយនឹងផលិតផលសរីរាង្គ ត្រូវប្រើទឹកស្អាត និងសារធាតុទាំងឡាយណាដែលមានរាយឈ្មោះក្នុងតារាងទី៤។

## ៥. ស្លាកសញ្ញា

**គោលបំណង**

ស្លាកសញ្ញាជាអត្តសញ្ញាណច្បាស់លាស់សម្រាប់សំគាល់ផលិតផលសរីរាង្គ និងផលិតផលកែច្នៃសរីរាង្គ ផ្តល់ព័ត៌មានជូនអតិថិជនដើម្បី ធ្វើការជ្រើសរើសឱ្យបានត្រឹមត្រូវ ជៀសវាងការភាន់ច្រឡំ។

**លក្ខខណ្ឌតម្រូវ**

៥.១-ស្លាកសញ្ញាត្រូវបង្ហាញពីសមាសភាពនៃធាតុផ្សំទាំងអស់ទៅតាមខ្នាតត្រឹមត្រូវ និងត្រូវបញ្ជាក់ថា ធាតុផ្សំនោះ មាន ឬពុំមានលក្ខណៈសរីរាង្គ។ ពពួករុក្ខជាតិយកក្លិន យកពណ៌ និង/ឬ រុក្ខជាតិហិរ ដែលមិនមែនសរីរាង្គ ត្រូវប្រើប្រាស់ក្នុងកម្រិតតិចជាង ២% នៃទម្ងន់សរុបរបស់ផលិតផលកែច្នៃ ហើយត្រូវបង្ហាញនៅក្នុងសមាសភាពនៃធាតុផ្សំ។

៥.២-ស្លាកសញ្ញាត្រូវបញ្ជាក់អំពីឈ្មោះអ្នកផលិត ដែលមានការទទួលស្គាល់ និងឈ្មោះអង្គភាពផ្តល់វិញ្ញាបនបត្រកសិកម្មសរីរាង្គ។ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកផលិត រោងចក្រផលិត អ្នកវេចខ្ចប់ ឬអ្នកផ្គត់ផ្គង់ចែកចាយ និងពាណិជ្ជសញ្ញា ដែលបានចុះបញ្ជីក៏ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ផងដែរ។ ចំពោះផលិតផលនាំចេញ ត្រូវដាក់បញ្ចូលឈ្មោះប្រទេសប្រភពដើមផលិតទៅក្នុងស្លាកសញ្ញា។

៥.៣-ស្លាកសញ្ញាត្រូវបញ្ជាក់ថាជា "ផលិតផលកែច្នៃសរីរាង្គ" ប្រសិនបើមានផ្ទុកធាតុផ្សំសរីរាង្គយ៉ាងហោច ៩៥% (គិតជាទម្ងន់ចំពោះវត្ថុរឹង ឬគិតជាចំណុះចំពោះអង្គធាតុរាវ លើកលែងតែទឹក និងអំបិល)។ មិនត្រូវប្រើប្រាស់ធាតុផ្សំមិនមែនសរីរាង្គ ដែលជាផលិតផលសារពាង្គកាយកែច្នៃស្សេណេទិច ឬដែលបានបាញ់កាំរស្មីបម្រែបម្រួលស្សេណេទិច ឬលាយជាមួយសារធាតុជំនួយផ្សេងទៀត ដែលមិនមានរំលេចក្នុងតារាងទី៥ក្នុងឧបសម្ព័នទី១ នៃវិធានកសិកម្មសរីរាង្គកម្ពុជានេះ។

៥.៤-ស្លាកសញ្ញាត្រូវបញ្ជាក់ថាជា "ផលិតផលកែច្នៃពីធាតុផ្សំសរីរាង្គ" ប្រសិនបើមានផ្ទុកធាតុផ្សំសរីរាង្គយ៉ាងហោច ៧០% (គិតជាទម្ងន់ចំពោះវត្ថុរឹង ឬគិតជាចំណុះចំពោះអង្គធាតុរាវ លើកលែងតែទឹក និងអំបិល)។

៥.៥-ផលិតផល ដែលមានធាតុផ្សំសរីរាង្គទាបជាង៧០% មិនទទួលស្គាល់ថាជាផលិតផលសរីរាង្គទេ។

៥.៦-ស្លាកសញ្ញា ត្រូវបែងចែកឱ្យដាច់ពីគ្នារវាងផលិតផលស្ថិតក្នុងរយៈពេលផ្លាស់ប្តូរ ឬអន្តរកាល និងផលិតផលសរីរាង្គ។ ស្លាកសញ្ញាដែលមានបង្ហាញពាក្យថា "សរីរាង្គ" ឬ "ផលិតផលស្ថិតក្នុងអំឡុងពេលផ្លាស់ប្តូរជាផលិតផលសរីរាង្គ" ត្រូវអនុលោមតាមវិធានកសិកម្មសរីរាង្គនេះ។

៥.៧-ផលិតផលសរីរាង្គ ដែលទទួលស្គាល់ដោយអង្គភាពចេញវិញ្ញាបនបត្រកសិកម្មសរីរាង្គត្រូវបង្ហាញឈ្មោះអង្គភាព និង/ឬ លេខកូដសម្គាល់វិញ្ញាបនបត្រនៅលើស្លាកសញ្ញា។

## ៦. ការប្រមូលត្រលប់មកវិញ និងការរក្សាកំណត់ត្រា

### គោលបំណង

ការរក្សាកំណត់ត្រា ជួយជានាដល់ការតាមដានអំពីលក្ខណៈសរីរាង្គនៅក្នុងដំណើរការផលិតកម្ម ឬការកែច្នៃទាំងមូលតាមរយៈការពិនិត្យមើលទិន្នន័យផលិតកម្ម ឬការកែច្នៃ (ឧ.ទិន្នន័យនៃវត្ថុធាតុដើមនិងធាតុចូលផ្សេងទៀត) និងទិន្នន័យបរិមាណនៅគ្រប់ដំណាក់កាលទាំងអស់នៃខ្សែច្រវាក់ផ្គត់ផ្គង់រួមទាំងដំណាក់កាលលក់ដូរផងដែរ។ កំណត់ត្រា ត្រូវមានតម្លាភាព និងភាពងាយស្រួលក្នុងការទទួលបានព័ត៌មានត្រលប់មកវិញ។

### លក្ខខណ្ឌតម្រូវ

៦.១-គ្រប់ទីកន្លែងនៃផលិតកម្ម ត្រូវដាក់ឈ្មោះ ឬលេខកូដផ្សេងៗគ្នា។ ឈ្មោះ ឬលេខកូដនេះ ត្រូវដាក់បង្ហាញនៅកន្លែងនីមួយៗជាក់ស្តែង និងត្រូវកត់ត្រានៅក្នុងផែនទីចម្ការឬកសិដ្ឋានក៏ដូចជាក្នុងគ្រប់ឯកសារទាំងអស់។

៦.២-អ្នកផលិត និងអ្នកកែច្នៃទាំងអស់ ត្រូវរក្សាទុកឯកសារកត់ត្រាការទិញ ការផលិត ការកែច្នៃ និងវត្ថុធាតុដើម ដែលប្រើសម្រាប់ការផលិត និងការកែច្នៃផលិតផលសរីរាង្គ ព្រមទាំងផលិតផលសម្រេច។

៦.៣-គ្រប់ឯកសារ និងកំណត់ត្រាទាំងអស់ ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ ពីប្រភព បំលាស់ទី ទិសដៅ ការប្រើប្រាស់ និងតារាងបញ្ជីសារធាតុសរីរាង្គ ដែលបានមកពីវត្ថុធាតុដើមមិនមែនសរីរាង្គ នៅគ្រប់ដំណាក់កាលនៃផលិតកម្ម និងការកែច្នៃផលិតផលសរីរាង្គ។

៦.៤-គ្រប់ឯកសារ ការកត់ត្រា និងបញ្ជីគណនេយ្យទាំងអស់ ត្រូវរៀបចំ ទុកដាក់ឱ្យបានល្អ ដើម្បីងាយស្រួលតាមដាននៅពេលត្រូវការ។

៦.៥-កំណត់ត្រា ដែលបានលើកឡើងខាងលើ(រួមទាំងកំណត់ត្រាពាក់ព័ន្ធនឹងអ្នកម៉ៅការបន្ត)ត្រូវរក្សាទុកយ៉ាងហោចណាស់រយៈពេល០៥ឆ្នាំ ដោយគិតចាប់ពីថ្ងៃដាក់ពាក្យ។

## ៧. វិធានលើការប្រើប្រាស់សារធាតុផ្សេងទៀត ដែលមិនបានកំណត់ក្នុង តារាងទី១ ដល់ទី៤ នៃវិធានកសិកម្មសរីរាង្គកម្ពុជា

### គោលបំណង

ការប្រើប្រាស់សារធាតុផ្សេងៗ ត្រូវស្របទៅតាមគោលបំណងនៃវិធានកសិកម្មសរីរាង្គកម្ពុជា។

### លក្ខខណ្ឌតម្រូវ

៧.១-ដើម្បីប្រើប្រាស់សារធាតុទាំងឡាយក្រៅពីសារធាតុ ដែលមានរាយឈ្មោះក្នុងតារាងទី១ ដល់ទី៤ សារធាតុទាំងនោះត្រូវគោរពតាមលក្ខណៈវិនិច្ឆ័យទាំងអស់ដូចខាងក្រោម៖

៧.១.១-សារធាតុទាំងនោះត្រូវស្របជាមួយគោលបំណងនៃផលិតកម្មកសិកម្មសរីរាង្គ

៧.១.២-ការប្រើប្រាស់សារធាតុទាំងនោះត្រូវមានភាពចាំបាច់

៧.១.៣-ការប្រើប្រាស់ និងការបោះចោលសារធាតុទាំងនោះ មិនត្រូវឱ្យប៉ះពាល់ដល់បរិស្ថាន

៧.១.៤-សារធាតុទាំងនោះ មិនត្រូវប៉ះពាល់ដល់សុខភាពមនុស្ស និងសត្វ

៧.១.៥-សារធាតុ ដែលអនុញ្ញាតដូចមានរាយឈ្មោះក្នុងតារាងទី១ ដល់ទី៤ មិនមានគ្រប់គ្រាន់សម្រាប់ប្រើប្រាស់គិតទាំងបរិមាណ និងគុណភាព។

៧.២-លក្ខណៈវិនិច្ឆ័យក្នុងចំណុចទី៧.១.១ ដល់ចំណុចទី៧.១.៥ មានគោលបំណងជារួមដើម្បីការពារភាពដាច់ខាតនៃផលិតកម្មសរីរាង្គ។ លើសពីនេះទៀត លក្ខណៈវិនិច្ឆ័យដូចខាងក្រោមត្រូវអនុវត្តតាមក្នុងដំណើរការវាយតម្លៃ៖

៧.២.១-ប្រសិនបើសារធាតុទាំងនោះ ត្រូវប្រើប្រាស់ធ្វើជាជី ឬជួយកែលម្អគុណភាពដីសារធាតុទាំងនោះត្រូវ បំពេញតួនាទីក្នុងការរក្សាជីជាតិដី និងផ្ដល់សារធាតុចិញ្ចឹមជាក់លាក់សម្រាប់បំពេញតម្រូវការរបស់ដំណាំ និងដី។ សារធាតុទាំងនោះ អាចមានប្រភពមកពីរុក្ខជាតិសត្វ មីក្រូសារពាង្គកាយ ឬសារធាតុរ៉ែធម្មជាតិ ដែលអាចធ្វើឱ្យកើតមានដូចជាដំណើរការរូបសាស្ត្រ (ឧ. មេកានិច និងដុតកំដៅ) ដំណើរការអង់ស៊ីម និង/ឬមីក្រូសារពាង្គកាយ។ ការប្រើប្រាស់សម្រាប់គោលបំណងខាងលើ មិនត្រូវប៉ះពាល់ដល់សរីរាង្គមានជីវិត និង/ឬលក្ខណៈរូបសាស្ត្ររបស់ដីឡើយ។

៧.២.២-ក្នុងករណីសារធាតុទាំងនោះ ត្រូវបានប្រើប្រាស់សម្រាប់គ្រប់គ្រង ជំងឺ សមាសភាពចង្រៃ សត្វល្អិត និងស្មៅចង្រៃ គួរជ្រើសរើសយកសារធាតុ ដែលអាចគ្រប់គ្រងភ្នាក់ងារបង្ករោគឬជំងឺពិសេសណាមួយ ដែលវិធានការរូបសាស្ត្រ ជីវសាស្ត្រ ការបង្កាត់ពូជ ឬបច្ចេកទេសគ្រប់គ្រងមានប្រសិទ្ធភាពផ្សេងទៀត មិនអាចអនុវត្តបាន។ សារធាតុទាំងនោះ ត្រូវមានប្រភពពីរុក្ខជាតិ សត្វ មីក្រូសារពាង្គកាយ ឬសារធាតុរ៉ែធម្មជាតិ ហើយអាចធ្វើឱ្យមានដំណើរការរូបសាស្ត្រ (មេកានិច និងដុតកំដៅ) អង់ស៊ីម និងមីក្រូសារពាង្គកាយ។ លើសពីនេះទៀត

សារធាតុសំយោគដូចជា ហ្សេរ៉ាម៉ូនអាចប្រើបានផងដែរ ប្រសិនបើសារធាតុដែលស្ថិតក្នុងទម្រង់ធម្មជាតិរបស់វាមិនអាចរកបានគ្រប់គ្រាន់។ ការប្រើប្រាស់សារធាតុខាងលើ មិនត្រូវបន្សល់ទុកសំណល់ដោយផ្ទាល់ ឬដោយប្រយោលក្នុងផ្នែកនៃកសិផលដែលអាចបរិភោគបាន។

៧.២.៣-ក្នុងករណីសារធាតុទាំងនោះ ត្រូវបានប្រើប្រាស់ជាសារធាតុបន្ថែមលើចំណីអាហារ ចំណីសត្វ ឬសារធាតុបន្ថែមលើការកែច្នៃ ដើម្បីរក្សាគុណភាពចំណីអាហារ សារធាតុទាំងនោះត្រូវមានប្រភពពីធម្មជាតិ និងអាចឆ្លងកាត់ដំណើរការរូបសាស្ត្រ ឬមេកានិច (ឧ.ការចម្រាញ់ ការសម្រក់ទឹក) ដំណើរការជីវសាស្ត្រ ឬអង់ស៊ីម និងដំណើរការមីក្រូសារពាង្គកាយ (ឧ.ការកាច់មេ)។ ក្នុងករណីសារធាតុខាងលើនេះ មិនអាចរកបានគ្រប់គ្រាន់ អាចប្រើប្រាស់សារធាតុសំយោគមួយចំនួនជំនួសបាន ប៉ុន្តែត្រូវធានាមិនបង្កការភាន់ច្រឡំដល់អ្នកប្រើប្រាស់ពាក់ព័ន្ធនឹងលក្ខណៈនៃសារធាតុ និងគុណភាពនៃចំណីអាហារឡើយ។

៧.៣-អ្នកពាក់ព័ន្ធទាំងអស់ អាចចូលរួមនៅក្នុងដំណើរការវាយតម្លៃបញ្ចូលសារធាតុទៅក្នុងបញ្ជី។

៧.៤-សំណើសុំបន្ថែមសារធាតុថ្មីទៅក្នុងតារាងទី១ ដល់ទី៤នៃឧបសម្ព័ន្ធទី១ នៃវិធានកសិកម្មសរីរាង្គកម្ពុជា គួរបញ្ចូលព័ត៌មានដូចខាងក្រោម៖

៧.៤.១-ការពិពណ៌នាពីផលិតផល និងលក្ខខណ្ឌនៃការប្រើប្រាស់ដែលរំពឹងថា មានលទ្ធផលល្អ។

៧.៤.២-ព័ត៌មានដែលបង្ហាញថាវិធានក្រោមចំណុចទី៧.១ ត្រូវបានបំពេញ។

## តារាងទី១៖ ជី និងសារធាតុកែលម្អដី

| សារធាតុ និងធាតុផ្សំ | លក្ខខណ្ឌប្រើប្រាស់ |
|---|---|
| **១. ប្រភពមកពីសត្វ និងរុក្ខជាតិ** | |
| ជីលាមកសត្វ (រាប់បញ្ចូលទាំងជីស្ងួត) កាកសំណល់ឡជីវឧស្ម័ន ទឹកនោម ជីកំប៉ុស្ត។ | ការប្រើប្រាស់លាមកពីកសិដ្ឋានក្នុងចំនួនមានកំណត់ ត្រូវបានអនុញ្ញាត ប៉ុន្តែការប្រើប្រាស់នេះត្រូវបំពេញលក្ខខណ្ឌពីរ៖<br>- ត្រូវឆ្លងកាត់ការវិភាគរកវត្តមានកាកសំណល់ដូចជា ថ្នាំបសុសត្វ ថ្នាំកសិកម្ម អ័រម៉ូន និងលោហៈធាតុធ្ងន់។<br>- ត្រូវបំលែងឱ្យទៅជាជីកំប៉ុស្តគោក ឬទឹកទាំងស្រុង។ |
| លាមកសត្វបក្សី (ប្រចៀវ ព្រាប ជ្រឹង...) | ត្រូវស្របទៅនឹងគោលការណ៍អភិរក្សធនធានពាក់ព័ន្ធ។ |
| ឈាម សាច់ ឆ្អឹង | កាកសំណល់ទាំងនេះ អាចប្រើប្រាស់បានពីប្រភពដែលទទួលស្គាល់ដោយអង្គភាពមានសមត្ថកិច្ច ក្នុងករណីមានការខ្វះខាត អាចប្រើប្រាស់ពីប្រភពផ្សេង ប៉ុន្តែត្រូវមានការអនុញ្ញាតត្រឹមត្រូវ។ |
| ស្នែង ក្រចក រោម ត្រី និងផលិតផលធ្វើពីត្រី ផលិតផលទឹកដោះ | កាកសំណល់ទាំងនេះ អាចប្រើប្រាស់បានពីប្រភពដែលទទួលស្គាល់ដោយអង្គភាពមានសមត្ថកិច្ច ក្នុងករណីមានការខ្វះខាត អាចប្រើប្រាស់ពីប្រភពផ្សេង ប៉ុន្តែត្រូវមានការអនុញ្ញាតត្រឹមត្រូវ។ |

| | |
|---|---|
| អនុផលកែច្នៃដែល អាចបំលែងដោយភ្នាក់ងារជីវសាស្ត្រ ផលិតផលធ្វើពីសត្វ និងរុក្ខជាតិ ឧទាហរណ៍ កាកសំណល់បានមកពីការកែច្នៃអាហារ ចំណីសត្វ ប្រេងរុក្ខជាតិ ស្រាបៀរ ស្រា ស្ករ និងវាយនភ័ណ្ឌ (មិនអនុញ្ញាតឱ្យប្រើសារធាតុសំយោគបន្ថែម)។ | អនុផល មិនត្រូវមានប្រភពពីផលិតផលសារពាង្គកាយកែច្នៃស្សេណេទិច។ |
| អនុផលបានមកពីដូងប្រេង ដូង និងកាកាវ (រួមមានស្នែង ស្រកីដូង កំទេចស្រកីដូង កាកដូង ធ្យូងអង្កាម សំបកពពួកសណ្តែក អាចម៍រណា កាកអំពៅ ដើមសំបក ស្នូល ពោត ) | មានប្រភពមកពីកសិដ្ឋានដែលប្រើថ្នាំកសិកម្មស្របតាមបច្ចេកទេសណែនាំ ក្នុងករណីមានការខ្វះខាតអាចប្រើប្រាស់ពីប្រភពផ្សេង ប៉ុន្តែត្រូវមានការអនុញ្ញាតត្រឹមត្រូវ។ |
| អនុផលបានមកពីការកែច្នៃក្នុងឧស្សាហកម្មមានជាតុផ្សំមកពីកសិកម្មសរីរាង្គ។ | |
| កាកសំណល់បន្លែ និងដំណាំ កំទេចកំទីគ្របពីលើរងដំណាំ ជីស្រស់ ចំបើង និង ពពួកចក។ | មានប្រភពត្រឹមត្រូវ ដែលអនុញ្ញាតឱ្យប្រើប្រាស់បាន។ |
| ឈើ សំបកឈើ កំទេចឈើ ផេះ ធ្យូងឈើ ទឹកខ្មេះឈើ ឫស្សី ឬអង្កាម។ | មិនត្រូវប្រើសារធាតុគីមីសម្រាប់ត្រាំ។ |
| ផលិតផល និងអនុផលសារ៉ាយសមុទ្រ និងស្លែ | មានប្រភពត្រឹមត្រូវ ដែលអនុញ្ញាតឱ្យប្រើប្រាស់បាន។ |
| មមោក (ហាមឃាត់ប្រើប្រាស់ធ្វើជាសារធាតុកែលម្អ) | មិនរាប់បញ្ចូលនូវសារធាតុសំយោគបន្ថែម អនុញ្ញាតឱ្យដាក់បញ្ចូលល្បាយជីលាយក្នុងផើង។ មិនអនុញ្ញាតឱ្យប្រើជាសារធាតុកែលម្អដី។ |
| កាកសំណល់រុក្ខជាតិបានមកពីការកែច្នៃរួច (ដំណាំយកម្សៅ យកប្រេង សរសៃ) | ត្រូវមានប្រភពដើមពីកសិកម្មសរីរាង្គ |
| ជីកំប៉ុស្តផលិតពីជាតុផ្សំដូចមានចែងនៅក្នុងឧបសម្ព័ន្ធនេះ កាកសំណល់ផ្សិតបោះចោល សារធាតុមមោកកើតពីជន្លេន និងសត្វល្អិត និងសារធាតុបានមកពីការចិញ្ចឹមជង្គង់នាង។ | សារធាតុផ្សំត្រូវប្រើតែផលិតផលដែលមានរាយឈ្មោះក្នុងតារាងនេះ ។ |

| | |
|---|---|
| កាកសំណល់ស្ងួត ឬកាកសំណល់រលួយ | ត្រូវចេញពីប្រភពបែងចែកច្បាស់លាស់ មិនឱ្យមានភាពចម្លង ឬលាយឡំជាតុកខ្វក់)។ |
| សារពាង្គកាយជីវសាស្ត្រមានប្រភពពីធម្មជាតិដូចជាជន្លេន | មានប្រភពត្រឹមត្រូវ ដែលអនុញ្ញាតឱ្យប្រើប្រាស់បានតាមបច្ចេកទេស។ |
| ផលិតផលជី ជីវសរីរាង្គ | សារធាតុផ្សំត្រូវប្រើតែផលិតផលដែលមានរាយឈ្មោះក្នុងតារាងនេះ។ |
| **២. ប្រភពមកពីរ៉ែ** | |
| ដីល្បាប់ | |
| សារធាតុកែលម្អម៉ាញ៉េស្យូម និងជាតិកំបោរ | មានប្រភពពីរ៉ែធម្មជាតិ |
| ថ្មកំបោរ កំបោរ ដីស ធ្យូងជីវកាកអំពៅ និងអង្កាម | មានប្រភពត្រឹមត្រូវ ស្របតាមបច្ចេកទេសណែនាំក្នុងការប្រើប្រាស់ |
| សូលុយស្យុងកាល់ស្យូមក្លរីត | ប្រើបាញ់ទៅលើស្លឹកពេលខ្វះសារធាតុកាល់ស្យូម |
| កំបោរក្លរីត | មានប្រភពត្រឹមត្រូវ ស្របតាមបច្ចេកទេសណែនាំក្នុងការប្រើប្រាស់ |
| Gypsum (កាល់ស្យូមស៊ុលផាត ឬកំបោរកសិកម្ម) | មានប្រភពពីធម្មជាតិតែប៉ុណ្ណោះ |
| ថ្មម៉ាញ៉េស្យូម គីសេរីត និងអំបិលរ៉ែ Epsom (ម៉ាញ៉េស្យូមស៊ុលផាត) | មានប្រភពត្រឹមត្រូវ ស្របតាមបច្ចេកទេសណែនាំក្នុងការប្រើប្រាស់ |
| អំបិលប៉ូតាស្យូម (ឧទាហរណ៍ ប៉ូតាស្យូមស៊ុលផាត ប៉ូតាស្យូមក្លរ kainite sylvanite និង patentkali) | បានមកតាមរយៈប្រតិកម្មរូបសាស្ត្រ ប៉ុន្តែមិនបានបង្កើនសារធាតុចិញ្ចឹមតាមរយៈប្រតិកម្មគីមីឡើយ។ ក្លរីនតិចជាង ៦០%។ |
| ផូស្វាតធម្មជាតិ ឧទាហរណ៍ ថ្មផូស្វាត | សារធាតុកាតមីញ៉ូមមិនគួរលើសពី ៩០មក្រ. ក្នុងមួយ គក្រ. $P_2O_5$ |
| កំទេចថ្ម និងថ្មម៉ត់ | មានប្រភពមកពីធម្មជាតិ ដែលអាចប្រើប្រាស់បាន ស្របតាមបច្ចេកទេសណែនាំក្នុងការប្រើប្រាស់។ |
| ដីឥដ្ឋ (ឧទាហរណ៍ ប៊ែនតូនីក ពែរលីត វើមីគូលីត ហ្សូលីត) | មានប្រភពត្រឹមត្រូវ ស្របតាមបច្ចេកទេសណែនាំក្នុងការប្រើប្រាស់ |

| | |
|---|---|
| សូដ្យូមក្លរីត | ប្រភពមកពីអំបិលរ៉ែ |
| សារធាតុគីមីបន្តិចបន្តួច | មានប្រភពត្រឹមត្រូវ ស្របតាម បច្ចេកទេសណែនាំក្នុងការប្រើប្រាស់ |
| ស៊ុលផួរ | មានប្រភពត្រឹមត្រូវ ស្របតាម បច្ចេកទេសណែនាំក្នុងការប្រើប្រាស់ |
| បាយស្រា និង ជាតុចម្រាញ់ចេញពីបាយស្រា[១] | មិនរាប់បញ្ចូលអាម៉ូញ៉ូមក្នុងបាយស្រា |
| ផូស្វាតកាល់ស្យូមអាលុយមីញ៉ូម | សារធាតុកាតមីញ៉ូមមិនត្រូវលើសពី ៩០មក្រ. ក្នុងមួយ គក្រ. $P_2O_5$ |
| **៣. សារពាង្គកាយ** | |
| អនុផលមានប្រភពពីវត្ថុ ដែលអាចបំលែង ជីវសាស្ត្របាន ឧទាហរណ៍ អនុផលបានមកពីការ ផលិតស្រាបៀរ ឬការបិតស្រា | មានប្រភពត្រឹមត្រូវ ស្របតាម បច្ចេកទេសណែនាំក្នុងការប្រើប្រាស់ |
| ការរៀបចំមីក្រូជីវសាស្ត្រ មានប្រភពពីភាវរស់មាន នៅក្នុងធម្មជាតិ | ពពួកភ្នាក់ងារជីវសាស្ត្រដែលបាន មកពីធម្មជាតិ |
| **៤. ប្រភពផ្សេងទៀត** | |
| ការរៀបចំជីវសាស្ត្រឌីណាមិក | សារធាតុផ្សំ ត្រូវប្រើតែផលិតផល ដែលមានរាយឈ្មោះក្នុងតារាងនេះ |

១ បាយស្រាគឺជាកាកធញ្ញជាតិដែលសល់ពីការបិតស្រាអង្ករ ប្រើសម្រាប់ធ្វើជាចំណីសត្វ។

## តារាងទី២៖ សារធាតុការពារ សារធាតុជំរុញការលូតលាស់ និងប្រព្រឹត្តិកម្មគ្រាប់ពូជ

| សារធាតុ និងធាតុផ្សំ | លក្ខខណ្ឌប្រើប្រាស់ |
|---|---|
| **១. ប្រភពមកពីសត្វ និងរុក្ខជាតិ** | |
| ធាតុផ្សំមានប្រភពពីអាហ្គា (ម្សៅចាហួយ) ឧទាហរណ៍ ចម្រាញ់ចេញពីសារ៉ាយសមុទ្រ | មានប្រភពត្រឹមត្រូវ ស្របតាមបច្ចេកទេសណែនាំក្នុងការប្រើប្រាស់ |
| ធាតុផ្សំមានប្រភពពីសត្វ និងប្រេង ឧទាហរណ៍ សារធាតុចម្រាញ់ចេញពីត្រី | មានប្រភពត្រឹមត្រូវ ស្របតាមបច្ចេកទេសណែនាំក្នុងការប្រើប្រាស់ |
| ក្រមួនឃ្មុំ | មានប្រភពត្រឹមត្រូវ ស្របតាមបច្ចេកទេសណែនាំក្នុងការប្រើប្រាស់ |
| ថ្នាំគីទីន កំចាត់ណេម៉ាតូត | មានប្រភពពីធម្មជាតិ |
| សំបក ឬកាកកាហ្វេ | មានប្រភពពីកសិកម្មសរីរាង្គ |
| ម្សៅពោតដំណើប គ្លុយតែន | សម្រាប់គ្រប់គ្រងស្មៅចង្រៃ |
| ផលិតផលទឹកដោះ (ឧទាហរណ៍ ទឹកដោះ កាសេអ៊ីន) | មានប្រភពត្រឹមត្រូវស្របតាមបច្ចេកទេសណែនាំក្នុងការប្រើប្រាស់ |
| សារធាតុអន្ទិល | មានប្រភពមកពីធម្មជាតិ |
| សារធាតុខ្លាញ់ពណ៌លឿងត្នោតឡេស៊ីទីន | មានប្រភពត្រឹមត្រូវ ស្របតាមបច្ចេកទេសណែនាំក្នុងការប្រើប្រាស់ |
| សារធាតុចម្រាញ់ចេញពីផ្សិត (ផ្សិត Shiitake) | មានប្រភពមកពីធម្មជាតិ |
| អាស៊ីតធម្មជាតិ (ឧទាហរណ៍ ទឹកខ្មេះ) | មានប្រភពមកពីធម្មជាតិ |
| ធាតុផ្សំ ឬផលិតផលមានប្រភពពីស្តៅ Neem *(Azadirachta indica)* | មានប្រភពមកពីធម្មជាតិ |
| ប្រេងរុក្ខជាតិ | មានប្រភពមកពីកសិកម្មសរីរាង្គ |
| ធាតុផ្សំរុក្ខជាតិធម្មជាតិ ដូចជាម្សៅគ្រាប់តែ សារធាតុចម្រាញ់ពីកន្ទួយត្រី។ | មានប្រភពមកពីធម្មជាតិ |
| សារធាតុបណ្តេញសត្វចង្រៃសម្រាប់ប្រើលើរុក្ខជាតិ ដូចជាទឹកផ្លែឈើផ្អាប់ សារធាតុចម្រាញ់ពីផ្កាស្ពៃរឿង។ | មានប្រភពមកពីកសិកម្មសរីរាង្គ |



Kដ្ឋ The

| | |
|---|---|
| ប្រូប៉ូលី | មានប្រភពមកពីធម្មជាតិ (ក្រមួនឃ្មុំ) |
| ជាតុផ្សំរបស់ពពួកផ្កាស្បៃរឿង (គ្រីសង់តែម) *Chrysanthemum cinerariaefolium*។ | ហាមឃាត់ចំពោះសារជាតុសំយោគ synergist Piperonyl butoxide |
| ជាតុផ្សំមានប្រភពពីរុក្ខជាតិ *Quassia amara* (*ដើមបាយក្តាំង*) | មានប្រភពមកពីធម្មជាតិ |
| ជាតុផ្សំរបស់ Rotenone ពីរុក្ខជាតិ Derris *elliptica* (*វល្លិ៍អន្ទង់*), *Lonchocarpus* *និង* *Thephrosia* spp. ) | បង្ការកុំឱ្យហូរចូលក្នុងប្រព័ន្ធទឹក មានប្រភពមកពីធម្មជាតិ |
| ជាតុផ្សំមានប្រភពពី *Ryania speciosa* | មានប្រភពមកពីធម្មជាតិ |
| រុក្ខជាតិ Sabadilla[៣] | Sabadilla មានប្រភពមកពីគ្រាប់ Sabadilla lily–រុក្ខជាតិមានប្រភពមកពីអាមេរិកខាងត្បូង |
| រុក្ខជាតិដែលមាន សារជាតុនីកូទីនសុទ្ធត្រូវបានហាមឃាត់ | តែ និងថ្នាំជក់ត្រូវបានហាមឃាត់ |
| សារជាតុសម្លាប់សត្វល្អិតSpinosad | សារជាតុនេះប្រើបាននៅពេល មានបំណងកាត់បន្ថយហានិភ័យជាអប្បបរមាទៅលើពពួកប៉ារ៉ាស៊ីត និងពពួកកូនដង្កូវដែលមានភាពស៊ាំ។ លក្ខខណ្ឌតម្រូវការណែនាំ និងកម្រិតប្រើប្រាស់ត្រូវទទួលស្គាល់ដោយអង្គភាពចេញវិញ្ញាបនបត្រ។ |
| សារ៉ាយសមុទ្រ អាហារធ្វើពីសារ៉ាយសមុទ្រ ជាតុចម្រាញ់ពីសារ៉ាយសមុទ្រ | មានប្រភពមកពីធម្មជាតិ |
| ផេះ | មានប្រភពមកពីធម្មជាតិ |
| **២. ប្រភពមកពីរុក្ខជាតិក្នុងស្រុក** | |
| ផ្លែស្លាក់ និងស្លឹកប្រេងខ្យល់ (មានសារជាតុ អាចបំពុល និងបណ្តេញសត្វល្អិតបាន) | ប្រើសម្រាប់ការពារពីការបំផ្លាញដំណាំពីពពួកស្រឹងបែតង ដង្កូវហ្វូង និងដង្កូវកាត់ស្លឹក |
| ក្តួច (អាចបំពុលសត្វល្អិតចង្រៃបាន) ជ័រក្តិបល្មុង (អាចកំចាត់សត្វល្អិតបានយ៉ាងមានប្រសិទ្ធភាព) | ប្រើសម្រាប់បំពុល និងកំចាត់ដង្កូវស៊ីបណ្តូលស្លែ ដង្កូវយោលទោង |

| | |
|---|---|
| សារធាតុហិរ ល្វីង និងមានក្លិន (ម្ទេស រំដេង ស្លឹក ឬសំបកស្លាក់ និងវល្លិ៍មាស) | អាចបណ្តេញ និងធ្វើឱ្យពុលដល់សត្វល្អិតចង្រៃដូចជា ទៀកតូ ចៃ រុយចោះផ្លែ និងដង្កូវមូលស្លឹក នៅពេលយើងលាយបញ្ចូលគ្នា |
| សារធាតុល្វីង ពុល និងមានក្លិន ដែលសត្វល្អិតមិនចូលចិត្ត (ថ្នាំជក់ បណ្តូលចេក ស្លែងធំ ស្លឹកគ្រៃ ស្លឹកម្រះ) | អាចកំចាត់ និងបណ្តេញសត្វល្អិតចង្រៃដូចជា ដង្កូវកាត់ដើម ដង្កូវឃោលទោងកណ្តូប អណ្តើកមាសកវែង នៅពេលយើងលាយបញ្ចូលគ្នា |
| សារធាតុ ល្វីង ហិរ ជូរ (ស្លែង ស្លឹកស្តៅ ថ្នាំជក់ ក្តូច រំដេង ម្ទេស និងក្រូចឆ្មា) | អាចបណ្តេញឬកំចាត់សត្វល្អិតចង្រៃ (ទៀកតូ ចៃ ដង្កូវម្ទូរស្លឹក ទ្រីបស្រមោច ដង្កូវឃោលទោង និងពីងពាងក្រហម) នៅពេលយើងលាយបញ្ចូលគ្នា |
| សារធាតុហិរ និងក្រពុល (ស្លឹកទៀប គ្រាប់ប៊ិគក់ និងម្ទេស) | អាចបំពុល និងបណ្តេញ សត្វល្អិតចង្រៃ (ដង្កូវកាត់ដើម អណ្តើកមាសកវែង ចៃ មមាចខៀវកណ្តូប និងដង្កូវនានា) |
| សារធាតុហិរ (ស្លឹកប្រេងខ្យល់ និងម្ទេស) និងសារធាតុពុល (ផ្លែស្លែង និងថ្នាំជក់) | អាចបំពុល និងបណ្តេញ សត្វល្អិតចង្រៃ(ដង្កូវឃោលទោង និងដង្កូវស៊ីបណ្តូលស្ពៃ ដង្កូវស៊ីញ៉េដង្កូវស៊ីស្លឹក ពពួកចៃ ទៀកតូ) |
| ស្តៅ បណ្តូរពេជ្រ និងរំដេង | ប្រើសំលាប់សត្វល្អិត និងបណ្តេញរារាំងការស៊ីចំណី និងបង្អាក់ការលូតលាស់ដូចជា៖ រុយស ដង្កូវហ្វូងដង្កូវបាក់ខ្នង ដង្កូវឃោលទោង និងដង្កូវម្ទូរស្លឹក |
| ថ្នាំជក់សំលាប់ ក្តូច រំដេង ស្លឹកគ្រៃ និងស្តៅ | អាចបំពុល សម្លាប់ និងបណ្តេញ សត្វល្អិតចង្រៃដូចជា៖ ដង្កូវម្ទូរស្លឹកដង្កូវចោះផ្លែ ដង្កូវហ្វូង ដង្កូវកាត់ស្លឹកពីងពាងក្រហម ចៃ រុយចោះផ្លែ |

| | |
|---|---|
| ស្លឹកទៀបបាយ និងប្រេងខ្យល់មានសារជាតុដែលអាចសំលាប់ និងបណ្តេញសត្វល្អិត | សម្រាប់កម្ចាត់ មមាចបៃតង ទ្រីប ចៃ រុយស |
| មើមខ្ទឹមស និងប្រេងឆា | ប្រើសម្រាប់បាញ់ទៅលើរុក្ខជាតិដើម្បីកម្ចាត់មមាចបំផ្លាញស្លឹក ដង្កូវ ស្រឹង និងរុយស |
| ប្រេងចម្រាញ់ពីគ្រាប់ស្តៅ | ប្រើសម្រាប់បាញ់ទៅលើរុក្ខជាតិដើម្បីកម្ចាត់មមាចបំផ្លាញស្លឹក ដង្កូវ ទាកគួរ និងចៃ |
| សារជាតុផ្សំពី មើមខ្ញី ខ្ទឹមស និងម្ទេស | ប្រើសម្រាប់បាញ់ទៅលើរុក្ខជាតិដើម្បីកម្ចាត់មមាចបំផ្លាញស្លឹក ដង្កូវហ្វូង មេអំបៅ ដង្កូវចោះផ្លែ ដង្កូវផែនទី ដង្កូវចោះចុងមែក ទ្រីប រុយស និងចៃ |
| **៣. ប្រភពមកពីរ៉ែ** | |
| កំបោរក្លរីត | មានប្រភពមកពីធម្មជាតិ |
| ដីឥដ្ឋ ( ឧទាហរណ៍ ប៊ែនតូនីក ពែរលីត វែមីគូលីត ហ្សូលីត ) | មានប្រភពមកពីធម្មជាតិ |
| អំបិលទង់ដែង ( ឧទាហរណ៍ ស៊ុលផាត អ៊ីដ្រុកស៊ីត អុកស៊ីក្លរីត អុកតានណូអាត ស្ពាន់អុកស៊ីត ល្បាយប័រ និងល្បាយស្រាទំពាំងបាយជូរ | តម្រូវការ ការណែនាំ និងកម្រិតប្រើប្រាស់ត្រូវតែទទួលស្គាល់ដោយអង្គភាពចេញវិញ្ញាបនបត្រ។ ជាថ្នាំកំចាត់ផ្សិត ដែលត្រូវប្រើក្នុងលក្ខខណ្ឌកាត់បន្ថយឱ្យបានជាអប្បរមា នូវការបង្កបង្កើត សារជាតុទង់ដែងនៅក្នុងដី។ ការប្រើប្រាស់ថ្នាំ ដែលមានសារជាតុទង់ដែងគួរប្រឹក្សាយោបល់ជាមួយអ្នកបច្ចេកទេសកសិកម្មសរីរាង្គដែលនៅជិត។ |
| ផូស៊ីលឌីអាតូមីត | |
| ប្រេងរ៉ែរលោង ( ប៉ារ៉ាហ្វីន ) | |
| កំបោរស៊ុលផួរ ( កាល់ស្យូមប៉ូលីស៊ុលហ្វីត ) | |
| ដែកផូស្វាត | ថ្នាំកម្ចាត់ខ្យង |

| | |
|---|---|
| ប៉ូតាស្យូមប៊ីកាបូណាត | |
| ប៉ូតាស្យូមពែម៉ង់កាណាត | |
| កំបោររស់ | |
| ស៊ីលីកាត ( ឧទាហរណ៍ សូដ្យូមស៊ីលីកាត ) | |
| សូដ្យូមប៊ីកាបូណាត | |
| ស៊ុលផួរ | តម្រូវឱ្យមានការអនុញ្ញាតដោយអង្គភាពចេញវិញ្ញាបនបត្រ។ |
| ម្សៅរ៉ែ (ម្សៅថ្ម ស៊ីលីកាត) | បំពេញបន្ថែមលក្ខខណ្ឌប្រើប្រាស់គ្រប់ចំណុច |
| **៤. សារពាង្គកាយ** | |
| ការរៀបចំជីវសាស្ត្រសម្រាប់បណ្ដុះផ្សិត | មានប្រភពមកពីមីក្រូសរីរាង្គ |
| ការរៀបចំបណ្ដុះបាក់តេរី ( ឧទាហរណ៍ *ផ្សិត Bacillus thuringiensis*) | មានប្រភពមកពីមីក្រូសរីរាង្គ |
| ការលែងប៉ារ៉ាសិត ប្រេដាទ័រ សត្វល្អិតដែលគ្មានផ្ទុកវីរុស ឧទាហរណ៍ *Trichogramma* ឱម៉ាល់អណ្ដើកមាស។ | មានប្រភពមកពីពពួកសត្វល្អិតមានប្រយោជន៍ |
| ជាតុផ្សំសម្រាប់បណ្ដុះវីរុស ( ឧទាហរណ៍ ជំងឺវីរុស) | មានប្រភពមកពីមីក្រូសរីរាង្គ |
| **៥. ប្រភពផ្សេងៗ** | |
| ការរៀបចំផ្សំពីរុក្ខជាតិមានក្លិន និងជីវឌីណាមិក | មានប្រភពមកពីធម្មជាតិ |
| កាល់ស្យូមអ៊ីដ្រុកស៊ីត | |
| ឧស្ម័នកាបូនិក និងឧស្ម័នអាសូត | |
| អេទីលអាកុល (អេតាណុល) | |
| អេទីឡែន | សម្រាប់កម្ចាត់រុយចោះផ្លែឈើ និងជាសារជាតុជំរុញឱ្យចេញផ្កានៅលើដំណាំម្នាស់។ សម្រាប់បន្ទុំផ្លែស្វាយ ចេក និងផ្លែឈើតំបន់ត្រូពិកផ្សេងទៀត។ |
| ការរៀបចំផ្សំថ្នាំបុរាណនិងថ្នាំព្យាបាលរោគ | មានប្រភពមកពីធម្មជាតិ និងសរីរាង្គ |
| អំបិលសមុទ្រ និងទឹកអំបិល | មានប្រភពមកពីធម្មជាតិ |
| សូដា | |
| សាប៊ូប៉ូតាស្យូម (សាប៊ូទន់) | |

| | |
|---|---|
| ថ្នាំកំចាត់ពពួកសត្វកកេរ | តម្រូវការ ការណែនាំ និងកម្រិតប្រើប្រាស់ត្រូវមានការយល់ព្រមដោយអង្គភាពចេញវិញ្ញាបនបត្រ។ |
| ស៊ុលផ្ទួរឌីអុកស៊ីត | |
| ការកំចាត់ដោយប្រើកំដៅ | |
| ការរៀបចំតាមទំលាប់បុរាណ (មិនមែនជាប្រភេទគីមីសំយោគ) ផ្អែកទៅលើផលិតផលពីធម្មជាតិ | |
| ការរៀបចំធ្វើឱ្យជីវសាស្ត្រមានសកម្មភាពខ្លាំងក្លា | មានប្រភពមកពីមីក្រូសរីរាង្គ |
| ថ្នាំពុលជីវសាស្ត្រ ឬភ្នាក់ងារកំចាត់ជីវសាស្ត្រ | សារធាតុផ្សំត្រូវប្រើតែផលិតផល ដែលមានរាយឈ្មោះក្នុងតារាងនេះ។ |
| **៥. អន្ទាក់ រនាំង ថ្នាំបណ្ដេញសត្វល្អិតចង្រៃ** | |
| វិធីសាស្ត្ររូបសាស្ត្រ (ឧទាហរណ៍ អន្ទាក់ពណ៌ អន្ទាក់មេកានិច) | |
| ប្រេងរ៉ែ | |
| គម្របពីលើរងដំណាំ និងសំណាញ់ | |
| ហ្វេរ៉ូម៉ូន (អន្ទាក់ស្នេហ៍) | សម្រាប់ដាក់ក្នុងអន្ទាក់ និងឧបករណ៍បាញ់ថ្នាំប៉ុណ្ណោះ។ |

## តារាងទី៣៖ សារធាតុបន្ថែម និងសារធាតុជំនួយក្នុងការកែច្នៃ

តារាងខាងក្រោមនេះ ជាបញ្ជីសារជាតុបន្ថែម និងសារជាតុជំនួយក្នុងការកែច្នៃមាននៅក្នុងអាហារទូទៅ រួមទាំងសម្ភារសម្រាប់ផ្ទុក ដែលអនុញ្ញាតឱ្យប្រើនៅក្នុងផលិតកម្មអាហារសរីរាង្គ ដោយអនុលោមទៅតាមវិធានទូទៅសម្រាប់សារជាតុបន្ថែមនៃអាហារ និងវិធានផ្សេងទៀតដែលបានអនុម័តដោយគណៈកម្មការសុវត្ថិភាពចំណីអាហារ (Codex Alimentarius Commission)។

| លេខកូដអន្តរជាតិ | សារធាតុបន្ថែម | មុខងារប្រើប្រាស់ | ប្រភេទអាហារ | |
|---|---|---|---|---|
| | | | អាហារមានប្រភពពីរុក្ខជាតិ | អាហារមានប្រភពពីសាច់សត្វ |
| INS ១៧០i | កាល់ស្យូមកាបូណាត | ទាំងអស់ | អនុញ្ញាតឱ្យប្រើ ទោះជាគ្មានក្នុងបញ្ជី GSFA | ០១.០ ផលិតផលទឹកដោះ និងផលិតផលប្រហាក់ប្រហែល លើកលែងតែផលិតផលអាហារប្រភេទ ០២.០ |
| INS ២២០ | ស៊ុលផួរឌីអុកស៊ីត | ទាំងអស់ | ១៤.២.៣ ស្រាទំពាំងបាយជូរ ១៤.២.៤ ស្រា (ក្រៅពីទំពាំងបាយជូរ) ផលិតផលដែលផលិតពីដំណាំត្រូពិក ដូចជា ដូង ត្នោត ម្សៅដំឡូងមី | ១៤.២.៥ គេសជ្ជៈផលិតពីទឹកឃ្មុំ |
| INS ២២៤ | ប៉ូតាស្យូមមេតាប៊ីស៊ុលផាត | | ប្រើសម្រាប់តែស្រា (Wine) ប្រភេទស្រាផ្អាប់ | |

| | | | | |
|---|---|---|---|---|
| INS ២៧០ | អាស៊ីតឡាទិក | ទាំងអស់ | ០៤.២.២.៧ បន្លែផ្អាប់ (រួមមានផ្សិតបរិភោគ និងផ្សិត Fungi ឬស មើមពពួកសណ្តែក និងប្រទាល កន្ទុយក្រពើ) សារាយសមុទ្រ មិនរាប់បញ្ចូលផលិតផលសណ្តែកសៀងផ្អាប់នៃប្រភេទអាហារ១២.១០ | ០១.០ ផលិតផលទឹកដោះ និងផលិតផលប្រហាក់ប្រហែលស្រដៀងគ្នា លើកលែងតែផលិតផលអាហារប្រភេទ ០២.០<br>០.៨.៤ សំបក ស្រោមដែលអាចហូបបាន (ឧទាហរណ៍ ស្រោមសាច់ក្រក) |
| INS ២៩០ | ឧស្ម័នកាបូនិច | ទាំងអស់ | អនុញ្ញាតឱ្យប្រើ ទោះជាគ្មានក្នុងបញ្ជី GSFA[1] ក៏ដោយ។ | អនុញ្ញាតឱ្យប្រើ ទោះជាគ្មានក្នុងបញ្ជី GSFA ក៏ដោយ។ |
| INS ២៩៦ | អាស៊ីតម៉ាលីក (DL-) | ទាំងអស់ | អនុញ្ញាតឱ្យប្រើ ទោះជាគ្មានក្នុងបញ្ជី GSFA | មិនអនុញ្ញាត។ |
| INS ៣០០ | អាស៊ីតអាស្កប៊ីក | ទាំងអស់ | ក្នុងលក្ខខ័ណ្ឌប្រភពធនធានធម្មជាតិមានមិនគ្រប់គ្រាន់។<br>អនុញ្ញាតឱ្យប្រើ ទោះជាគ្មានក្នុងបញ្ជី GSFA | ក្នុងលក្ខខ័ណ្ឌប្រភពធនធានធម្មជាតិមានមិនគ្រប់គ្រាន់។<br>០៨.២ សាច់កែច្នៃ និងផលិតផលស៊ុត និងសាច់<br>០៨.៣ សាច់កិនម៉ត់សម្រាប់កែច្នៃ ផលិតផលស៊ុត និងសាច់។<br>០.៨.៤ សំបក ស្រោមដែលអាចហូបបាន (ឧទាហរណ៍ ស្រោមសាច់ក្រក) |

[1] GSFA: The "Codex General Standard for Food Additives" (GSFA, Codex STAN 192-1995) sets forth the conditions under which permitted food additives may be used in all foods, whether or not they have previously been standardized by Codex.

| | | | | |
|---|---|---|---|---|
| INS ៣០៦ | Tocopherols (លាយជាមួយកំហាប់ធម្មជាតិ) | ទាំងអស់ | អនុញ្ញាតឱ្យប្រើ ទោះជាគ្មានក្នុងបញ្ជី GSFA | រាល់ផលិតផលលាយជាមួយគ្នា ដែលអនុញ្ញាតស្របតាមវិធានទូទៅសម្រាប់សារជាតុបន្ថែមនៃអាហារ និងវិធានផ្សេងទៀត ដែលបានអនុម័តដោយគណៈកម្មការសុវត្ថិភាពចំណីអាហារ (Codex Alimentarius Commission) |
| INS ៣២២ | ឡេស៊ីទីន (បានមកដោយគ្មានប្រើសារជាតុរំលាយសរីរាង្គ និងសារជាតុធ្វើឱ្យស) | ទាំងអស់ | អនុញ្ញាតឱ្យប្រើ ទោះជាគ្មានក្នុងបញ្ជី GSFA | ០១.០ ផលិតផលទឹកដោះ និងផលិតផលប្រហាក់ប្រហែល លើកលែងតែផលិតផលអាហារប្រភេទ ០២.០ ទឹកដោះ:០២.០ ខ្លាញ់ និងប្រេង<br>១២.៦.១ ទឹកជ្រលក់ក្រោយការចម្រាញ់ (ឧទាហរណ៍ ម៉ាយ៉ូណេស ញាំសាលាដ)<br>១៣.១ អាហារផ្សំសម្រាប់ទារក និងអាហារផ្សំសម្រាប់មនុស្សធំ<br>១៣.២ អាហារបន្ថែមសម្រាប់ទារក និងកុមារ |
| INS ៣២៧ | កាល់ស្យូមឡាក់តាត | ទាំងអស់ | មិនអនុញ្ញាត។ | ០១.០ ផលិតផលទឹកដោះ និងផលិតផលប្រហាក់ប្រហែល លើកលែងតែផលិតផលអាហារប្រភេទ ០២.០ ទឹកដោះ: |

| | | | | |
|---|---|---|---|---|
| INS ៣៣០ | អាស៊ីតស៊ីទ្រីក | ទាំងអស់ | ០៤.០ បន្លែ និងផ្លែឈើ (រួមមានផ្សិតបរិភោគ និងផ្សិត Fungi ឫស មើម ពពួកសណ្ដែក និងប្រទាលកន្ទុយក្រពើ) សារាយសមុទ្រ គ្រាប់ឈ្មុយ (Nuts) និង គ្រាប់ធញ្ញជាតិ (Seed)។ | ជាសារធាតុបង្កកសម្រាប់ផលិតផលហ្រ្វូម៉ា និងស៊ុតផ្អិន<br>០១.៦ ហ្វ្រូម៉ា និងផលិតផលប្រហាក់ប្រហែល<br>០២.១ ខ្លាញ់ និងប្រេងសុទ្ធ<br>១០.០ ស៊ុត និងផលិតផលធ្វើពីស៊ុត |
| INS ៣៣១i | សូដ្យូមឌីអ៊ីដ្រូសែនស៊ីត្រាត | ទាំងអស់ | មិនអនុញ្ញាត | ០១.១.១.២ ទឹកដោះប័រ (សុទ្ធ) (ក្នុងកម្រិតមិនឱ្យវិវត្តទៅកេហ្វូម៉ា)។<br>០១.១.២ ភេសជ្ជៈធ្វើពីទឹកដោះសម្រាប់ផឹក (ឧទាហរណ៍ ទឹកដោះសូកូឡាកាកាវ ភេសជ្ជៈរសជាតិស៊ុត យ៉ាអួរពាវ ភេសជ្ជៈធ្វើពីកាកទឹកដោះ)។<br>០១.២.១.២ ទឹកដោះជូរ<br>០១.២.២ ទឹកដោះអន្ទីល (មិនវិវត្តទៅមុខ)។<br>០១.៣ ទឹកដោះខាប់ និងផលិតផលប្រហាក់ប្រហែល (សុទ្ធ) (មិនឱ្យវិវត្តទៅមុខ)។<br>០១.៤ ក្រែម (សុទ្ធ) និងផលិតផលប្រហាក់ប្រហែល (មិនវិវដ្តទៅ មុខ)។ |

| | | | | |
|---|---|---|---|---|
| | | | | ០១.៥.១ ម្សៅទឹកដោះ និងម្សៅក្រែម (សុទ្ធ) (មិនវិវដ្តទៅមុខ)។<br>០១.៦.១ ហ្វូម៉ាជ្រាយ (មិនវិវដ្តទៅមុខ)។<br>០១.៦.៤ ហ្វូម៉ាកែច្នៃ (សម្រាប់ចម្រាញ់យកប្រេង ប៉ុណ្ណោះ)<br>០១.៨.២ កាកទឹកដោះស្ងួត ផលិតផលធ្វើពីកាកទឹកដោះទឹកដោះ មិនរាប់បញ្ចូលហ្វូម៉ា កាកទឹកដោះ។<br>១០.២ ផលិតផលធ្វើពីស៊ុត។ |
| INS ៣៣២i | ប៉ូតាស្យូម<br>ឌីអ៊ីដ្រូសែន ស៊ីត្រាត | ទាំងអស់ | មិនអនុញ្ញាត។ | អនុញ្ញាតឱ្យប្រើ ទោះជាគ្មានក្នុងបញ្ជី GSFA |
| INS ៣៣៣ | កាល់ស្យូម ស៊ីត្រាត | ទាំងអស់ | អនុញ្ញាតឱ្យប្រើ ទោះជាគ្មានក្នុងបញ្ជី GSFA | ០១.០ ផលិតផលទឹកដោះ និងផលិតផលស្រដៀងគ្នា លើកលែងតែផលិតផលអាហារប្រភេទ ០២.០ |
| INS ៣៣៤ | អាស៊ីតតាតារិក | ទាំងអស់ | អនុញ្ញាតឱ្យប្រើ ទោះជាគ្មានក្នុងបញ្ជី GSFA | មិនអនុញ្ញាត។ |
| INS ៣៣៥i | ម៉ូណូសូដ្យូមតេត្រាត | ទាំងអស់ | ០៥.០ ដំណាប់ | មិនអនុញ្ញាត។ |

| | | | | |
|---|---|---|---|---|
| INS ៣៣៥ii | ឌីសូដ្យូម តេត្រាត | ទាំងអស់ | ០៧.២.១ នំ | មិនអនុញ្ញាត។ |
| INS ៣៣៦ii | ឌីប៉ូតាស្យូម តេត្រាត | ទាំងអស់ | ០៧.២.១ នំ | មិនអនុញ្ញាត។ |
| INS ៣៤១i | ម៉ូណូកាល់ស្យូម អ័រតូផូស្វាត | ទាំងអស់ | ០៦.២.១ ម្សៅ | មិនអនុញ្ញាត។ |
| INS ៣៤២ | អាម៉ូញ៉ូមផូស្វាត | ទាំងអស់ | កំណត់ត្រឹម ០.៣ ក្រ. ក្នុងមួយលីត្រនៃស្រា | |
| INS ៤០០ | អាស៊ីតអាហ្សុីនីត | ទាំងអស់ | អនុញ្ញាតឱ្យប្រើ ទោះជាគ្មានក្នុងបញ្ជី GSFA | ០១.០ ផលិតផលទឹកដោះ និងផលិតផល ស្រដៀងគ្នា លើកលែងតែផលិតផលអាហារ ប្រភេទ ០២.០ |
| INS ៤០១ | សូស្យូមអាហ្សុីណាត | ទាំងអស់ | អនុញ្ញាតឱ្យប្រើ ទោះជាគ្មានក្នុងបញ្ជី GSFA | ០១.០ ផលិតផលទឹកដោះ និងផលិតផលស្រដៀងគ្នា លើកលែងតែផលិតផលអាហារប្រភេទ ០២.០ រាល់ផលិតផលលាយជាមួយគ្នា ដែលអនុញ្ញាតស្របតាមវិធានទូទៅសម្រាប់សារធាតុបន្ថែមនៃអាហារ និងវិធានផ្សេងទៀតដែលបានអនុម័តដោយគណៈកម្មការសុវត្ថិភាពចំណីអាហារ (Codex Alimentarius Commission) |
| INS ៤០២ | ប៉ូតាស្យូមអាហ្សុីណាត | ទាំងអស់ | អនុញ្ញាតឱ្យប្រើ ទោះជាគ្មានក្នុងបញ្ជី GSFA | ០១.០ ផលិតផលទឹកដោះ និងផលិតផលស្រដៀងគ្នា លើកលែងតែផលិតផលអាហារប្រភេទ ០២.០ |



Kw KS

| | | | | |
|---|---|---|---|---|
| | | | | រាល់ផលិតផលលាយជាមួយគ្នា ដែលអនុញ្ញាតស្របតាមវិធានទូទៅសម្រាប់សារធាតុបន្ថែមនៃអាហារ និងវិធានផ្សេងទៀត ដែលបានអនុម័តដោយគណៈកម្មការសុវត្ថិភាពចំណីអាហារ<br>( Codex Alimentarius Commission ) |
| INS ៤០៦ | ម្សៅអាហ្គា | ទាំងអស់ | អនុញ្ញាតឱ្យប្រើ ទោះជាគ្មានក្នុងបញ្ជី GSFA | អនុញ្ញាតឱ្យប្រើ ទោះជាគ្មានក្នុងបញ្ជី GSFA |
| INS ៤០៧ | ស្លែ Carrageenan | ទាំងអស់ | អនុញ្ញាតឱ្យប្រើ ទោះជាគ្មានក្នុងបញ្ជី GSFA | ០១.០ ផលិតផលទឹកដោះ និងផលិតផល ស្រដៀងគ្នា លើកលែងតែផលិតផលអាហារ ប្រភេទ ០២.០ |
| INS ៤១០ | ការជំរសណ្តែក<br>Carob | ទាំងអស់ | អនុញ្ញាតឱ្យប្រើ ទោះជាគ្មានក្នុងបញ្ជី GSFA | ០១.១ ទឹកដោះ និងភេសជ្ជៈដែលមានលាយទឹកដោះ<br>០១.២ ផលិតផលធ្វើពីទឹកដោះជូរ និងទឹកដោះអន្ទីល( សុទ្ធ ) មិនរាប់បញ្ចូលប្រភេទអាហារ ០១.១.២ (ភេសជ្ជៈធ្វើពីទឹកដោះ )។<br>០១.៣ ទឹកដោះខាប់ និងផលិតផលប្រហាក់ប្រហែល<br>០១.៤ ក្រែម ( សុទ្ធ ) និងផលិតផលប្រហាក់ប្រហែល |

| | | | | |
|---|---|---|---|---|
| | | | | ០១.៥ ម្សៅទឹកដោះ និងម្សៅក្រែម និងម្សៅប្រហាក់ប្រហែល<br>០១.៦ ហ្វ្រូម៉ា និងផលិតផលប្រហាក់ប្រហែល<br>០១.៧ បង្អែមដាក់ទឹកដោះ(ឧ. បង្អែមសង់ខ្យារ ផ្លែឈើ ឬយ៉ាអួរសជាតិផ្សេងគ្នា)។<br>០១.៨.១ ផលិតផលធ្វើពីកាកទឹកដោះ និងកាកទឹកដោះរាវ មិនរាប់បញ្ចូលហ្វ្រូម៉ាធ្វើពីកាកទឹកដោះផ្សេងទៀត។<br>០៨.២ សាច់កែច្នៃ ផលិតផលស៊ុត និងសាច់ជាដុំធំ ឬកាត់ជាកង់ៗ។<br>០៨.១.២ សាច់ស្រស់ និងសាច់បក្សី<br>០៨.៣ សាច់កិនម៉ត់សម្រាប់កែច្នៃ និងសាច់បក្សី។<br>០.៨.៤ សំបក ស្រោមដែលអាចហូបបាន (ឧទាហរណ៍ ស្រោមសាច់ក្រក) |
| INS ៤១២ | សារធាតុអន្ទីលចេញពីរុក្ខជាតិ Guar | ទាំងអស់ | អនុញ្ញាតឱ្យប្រើ ទោះជាគ្មានក្នុងបញ្ជី GSFA | ០១.០ ផលិតផលទឹកដោះ និងផលិតផលប្រហាក់ប្រហែល មិនរាប់បញ្ចូលផលិតផល ០២.០ |

| | | | | |
|---|---|---|---|---|
| | | | | ៨.២.២ សាច់កែច្នៃចំអិនរួច និងសាច់បក្សី<br>៨.៣.២ សាច់កិនកែច្នៃចំអិនរួច និងសាច់បក្សី |
| INS ៤១៣ | សារធាតុអន្ទីលចេញពីរុក្ខជាតិ Tragacanth | ទាំងអស់ | អនុញ្ញាតឱ្យប្រើ ទោះជាគ្មានក្នុងបញ្ជី GSFA | អនុញ្ញាតឱ្យប្រើ ទោះជាគ្មានក្នុងបញ្ជី GSFA |
| INS ៤១៤ | សារធាតុអន្ទីលចេញពីរុក្ខជាតិអារ៉ាប៊ិច | ទាំងអស់ | ០២.០ ខ្លាញ់ និងប្រេង និងប្រេងចម្រាញ់ផ្សេងៗ។<br>០៥.០ ដំណាប់ | ០១.០ ផលិតផលទឹកដោះ និងផលិតផលប្រហាក់ប្រហែល មិនរាប់បញ្ចូលផលិតផល ០២.០<br>០២.០ ខ្លាញ់ និងប្រេង ព្រមទាំងប្រេងចម្រាញ់ផ្សេងៗ។<br>០៥.០ ដំណាប់ |
| INS ៤១៥ | សារធាតុអន្ទីលចេញពីរុក្ខជាតិសង់តាន | ទាំងអស់ | ០២.០ ខ្លាញ់ និងប្រេង និងប្រេងចម្រាញ់ ផ្សេងៗ។<br>០៤.០ បន្លែ និងផ្លែឈើ (រួមមានផ្សិតបរិភោគ និងផ្សិត Fungi ឫសមើម ពពួកសណ្តែក និងប្រទាលកន្ទុយក្រពើ) សារ៉ាយសមុទ្រ គ្រាប់ឈ្មុយ (Nuts) និង គ្រាប់ធញ្ញជាតិ (Seed)។ | មិនអនុញ្ញាត។ |

| | | | | |
|---|---|---|---|---|
| | | | ០៧.០ ជាតុផ្សំសម្រាប់ធ្វើនំ<br>១២.៧ សាលាដ (ឧទាហរណ៍ សាលាដម៉ាការ៉ូនី សាលាដដំឡូង)។ | |
| INS ៤១៦ | សារធាតុអន្ទីលចេញពីរុក្ខជាតិការាយ៉ា | ទាំងអស់ | អនុញ្ញាតឱ្យប្រើ ទោះជាគ្មានក្នុងបញ្ជី GSFA | មិនអនុញ្ញាត។ |
| INS ៤២២ | ឃ្លីសេរ៉ូល | ទាំងអស់ | ០៤.២.២.៥ បន្លែ រួមមាន (ផ្សិតបរិភោគ និងផ្សិត Fungi ឫស មម ពពួកសណ្តែក និងប្រទាលកន្ទុយក្រពើ) សារ៉ាយសមុទ្រ និងគ្រាប់ធញ្ញជាតិកែច្នៃ<br>០៤.២.២.៦ បន្លែ (រួមមាន ផ្សិតបរិភោគ និងផ្សិត Fungi ឫស មើម ពពួកសណ្តែក និងប្រទាលកន្ទុយក្រពើ)សារ៉ាយសមុទ្រ និងគ្រាប់ធញ្ញជាតិកែច្នៃ (ឧទាហរណ៍ បង្អែម ធ្វើពីបន្លែ ទឹកជ្រលក់ និងស្ករគ្រាប់ធ្វើពីបន្លែ) បន្ថែមលើប្រភេទអាហារ ០៤.២.២.៥ ។<br>០៤.២.២.៧ បន្លែជ្រក់ រួមមាន ផ្សិតបរិភោគ និងផ្សិត Fungi ឫស មើម ពពួកសណ្តែក និងប្រទាល | មិនអនុញ្ញាត។ |



Ak KS

| | | | | |
|---|---|---|---|---|
| | | | កន្ទុយក្រពើ)ផលិតផលសាច់យសមុទ្រ លើកលែងតែផលិតផលសណ្តែកសៀងផ្អាប់ក្នុងប្រភេទអាហារ ១២.១០។ ១២.២ រុក្ខជាតិគ្រឿងផ្សំ គ្រឿងហិរ គ្រឿងបន្ថែមរស់ជាតិ និងគ្រឿងជ្រក់ (ឧទាហរណ៍ អំបិលមី អំបិលម្ទេស អំបិលម្រេច)។ | |
| INS ៤៤០ | ប៉េកទីន(គ្មានចលនា) | ទាំងអស់ | អនុញ្ញាតឱ្យប្រើ ទោះជាគ្មានក្នុងបញ្ជី GSFA | ០១.០ ផលិតផលទឹកដោះ និងផលិតផលប្រហាក់ប្រហែល លើកលែងតែផលិតផលអាហារ ប្រភេទ ០២.០ |
| INS ៥០០ii<br>INS ៥០០iii | សូដ្យូមអ៊ីដ្រូសែនកាបូណាត<br>សូដ្យូមសេគ្វីកាបូណាត | ទាំងអស់ | ០៥.០ ដំណាប់<br>០៧.០ ធាតុផ្សំសម្រាប់ធ្វើនំ | ០១.០ ផលិតផលទឹកដោះ និងផលិតផលប្រហាក់ប្រហែល លើកលែងតែផលិតផលអាហារ ប្រភេទ ០២.០ |
| INS ៥០១i | ប៉ូតាស្យូមកាបូណាត | ទាំងអស់ | ០៥.០ ដំណាប់<br>០៦.០ ផលិតផលមានប្រភពពីគ្រាប់ធញ្ញជាតិ ពីឫស មើម និងសរសៃ និងពពួកសណ្តែក លើកលែងតែធាតុផ្សំសម្រាប់ធ្វើនំក្នុងប្រភេទអាហារ ០៧.០។<br>០៧.២ គ្រឿងផ្សំធ្វើនំទម្រង់ជាម្សៅ (ផ្អែម ប្រៃ ជូរ)និងការលាយចូលគ្នា។ | មិនអនុញ្ញាត។ |



Kh Ts Thv

| | | | | |
|---|---|---|---|---|
| INS ៥០៣ i<br>INS ៥០៣ ii | អាម៉ូញ៉ូម កាបូណាត<br>អាម៉ូញ៉ូមអ៊ីដ្រូសែន កាបូណាត | សារធាតុកែតម្រូវជាតិអាស៊ីត<br>ជាតុសម្រាប់បង្កើនរសជាតិ | អនុញ្ញាតឱ្យប្រើ ទោះជាគ្មានក្នុងបញ្ជី GSFA | មិនអនុញ្ញាត។ |
| INS ៥០៤i<br>INS ៥០៤ii | ម៉ាញ៉េស្យូម កាបូណាត<br>ម៉ាញ៉េស្យូមអ៊ីដ្រូសែន កាបូណាត | ទាំងអស់ | អនុញ្ញាតឱ្យប្រើ ទោះជាគ្មានក្នុងបញ្ជី GSFA | មិនអនុញ្ញាត។ |
| INS ៥០៨ | ប៉ូតាស្យូមក្លរីត | ទាំងអស់ | ០៤.០ បន្លែ និងផ្លែឈើ (រួមមាន ផ្សិតបរិភោគ និងផ្សិត Fungi ឫស មើម ពពួកសណ្តែក និងប្រទាល កន្ទុយក្រពើ) សារ៉ាយសមុទ្រ គ្រាប់ឈ្មុយ (Nuts) និង គ្រាប់ធញ្ញជាតិ (Seed)។<br>១២.៤ ស្ពៃជ្រក់<br>១២.៦.២ ទឹកជ្រលក់ធម្មតា (ឧទាហរណ៍ ទឹកប៉េងប៉ោះ ទឹកស៊ីអ៊ីវ ទឹកជ្រលក់ក្រែម ទឹកស្រូបសាលាដ៏ម៉ូខែន)។ | មិនអនុញ្ញាត។ |

| | | | | |
|---|---|---|---|---|
| INS ៥០៩ | កាល់ស្យូមក្លរីត | ទាំងអស់ | ០៤.០ បន្លែ និងផ្លែឈើ (រួមមាន ផ្សិតបរិភោគ និងផ្សិត Fungi ឫស មើម ពពួកសណ្តែក និងប្រទាល កន្ទុយក្រពើ) សារាយសមុទ្រ គ្រាប់ឈ្មុយ (Nuts) និងគ្រាប់ធញ្ញជាតិ (Seed)<br>០៦.៨ ផលិតផលសណ្តែកសៀង (លើកលែង ផលិតផលអាហារធ្វើពីសណ្តែកសៀងប្រភេទ ១២.៩ និង ផលិតផលអាហារធ្វើពីសណ្តែកសៀងផ្អាប់ប្រភេទ ១២.១០) ។<br>១២.៩.១ ផលិតផលប្រូតេអ៊ីនសណ្តែកសៀង។<br>១២.១០ ផលិតផលសណ្តែកសៀងផ្អាប់ | ០១.០ ផលិតផលទឹកដោះ និង ផលិតផលប្រហាក់ប្រហែល លើកលែងតែផលិតផលអាហារប្រភេទ ០២.០<br>០៨.២ សាច់កែច្នៃ និងសាច់បក្សី<br>០៨.៣ សាច់កិនម៉ត់ឆ្លងកាត់ការកែច្នៃ និងសាច់បក្សី<br>០៨.៤ សំបក ស្រោមដែលអាចហូបបាន (ឧទាហរណ៍ ស្រោមសម្រាប់ញាត់សាច់ក្រក) |
| INS ៥១១ | ម៉ាញ៉េស្យូមក្លរីត | ទាំងអស់ | ០៦.៨ ផលិតផលសណ្តែកសៀង (លើកលែង ផលិតផលអាហារធ្វើពីសណ្តែកសៀងប្រភេទ ១២.៩ និងផលិតផលអាហារធ្វើពីសណ្តែកសៀងផ្អាប់ប្រភេទ១២.១០ | មិនអនុញ្ញាត។ |

| | | | | |
|---|---|---|---|---|
| | | | ១២.៩.១ ផលិតផលប្រូតេអ៊ីនសណ្តែកសៀង។<br>១២.១០ ផលិតផលសណ្តែកសៀងផ្អាប់ | |
| INS ៥១៦ | កាល្ស្យូមស៊ុលផាត | ទាំងអស់ | ០៦.៨ ផលិតផលសណ្តែកសៀង (លើកលែង ផលិតផលអាហារធ្វើពីសណ្តែកសៀងប្រភេទ ១២.៩ និងផលិតផលអាហារផ្អាប់ធ្វើពីសណ្តែកសៀងប្រភេទ ១២.១០ ។<br>០៧.២.១ នំបារាំង នំដុត និងនំផែ (ឧ. ប្រភេទនំមានស្នូលផ្លែឈើ ឬប្រភេទដាក់សង់ខ្យា)។<br>១២.៨ ផ្សិតឡើងមេ និងផលិតផលប្រហាក់ប្រហែល។<br>១២.៩.១ ផលិតផលប្រូតេអ៊ីនសណ្តែកសៀង។<br>១២.១០ ផលិតផលផ្អាប់ធ្វើពីសណ្តែកសៀង។ | មិនអនុញ្ញាត។ |

| | | | | |
|---|---|---|---|---|
| INS ៥១៧ | អាម៉ូញ៉ូមស៊ុលផាត | ទាំងអស់ | ប្រើសម្រាប់តែស្រាដែលកំណត់ត្រឹម ០.៣ មក្រក្នុងមួយលីត្រ។ | |
| INS ៥២៤ | សូដ្យូមអ៊ីដ្រុកស៊ីត | ទាំងអស់ | ០៦.០ ផលិតផល និងគ្រាប់ធញ្ញជាតិផ្សេងទៀតមានប្រភពពីគ្រាប់ធញ្ញជាតិ ពីឫស មើម និងសរសៃ និងពពួកសណ្តែក លើកលែងតែជាតុផ្សំសម្រាប់ធ្វើនំក្នុងប្រភេទអាហារ ០៧.០។ ០៧.១.១.១ នំប៉័ងប្រើមេ និងនំប៉័ងមិនប្រើមេ ។ | មិនអនុញ្ញាត។ |
| INS ៥២៦ | កាល់ស្យូមអ៊ីដ្រុកស៊ីត | ទាំងអស់ | អាហារបន្ថែមពីលើម្សៅពោត | |
| INS ៥៥១ | ស៊ីលីកុង ឌីអុកស៊ីត (អម័រហ្វូស) | ទាំងអស់ | ១២.២ រុក្ខជាតិគ្រឿងផ្សំ គ្រឿងហិរ គ្រឿងបន្ថែមរស់ជាតិ និងគ្រឿងជ្រក់ (ឧទាហរណ៍ អំបិលមី អំបិលម្ទេស អំបិលម្រេច)។ | មិនអនុញ្ញាត។ |
| INS ៩៣៨ | អាហ្គុង | ទាំងអស់ | | |
| INS ៩៤១ | អាសូត | ទាំងអស់ | អនុញ្ញាតឱ្យប្រើ ទោះជាគ្មានក្នុងបញ្ជី GSFA | អនុញ្ញាតឱ្យប្រើ ទោះជាគ្មានក្នុងបញ្ជី GSFA |
| INS ៩៤៨ | អុកស៊ីសែន | ទាំងអស់ | | |



AWKS ឃ

## ធាតុផ្សំឱ្យមានរសជាតិ

១-សារធាតុ និងផលិតផលមានស្លាកសញ្ញាជាសារធាតុគ្រឿងផ្សំពីធម្មជាតិ ឬពីការរៀបចំ ត្រូវបានកំណត់នៅក្នុងលក្ខខណ្ឌតម្រូវទូទៅសម្រាប់សារធាតុគ្រឿងផ្សំរសជាតិតាមធម្មជាតិ (Codex Alimentarius Commission, CAC/GL ២៩-១៩៨៧)។

២-ការចម្រាញ់ពីធាតុផ្សំសរីរាង្គ (ដូចជា ប្រេងធា)។

៣-ប្រេងធា (ចាំបាច់) ដែលផលិតពីអង្គធាតុរំលាយដូចជាប្រេង ទឹក អេតាណុល ឧស្ម័នកាបូនិច និងដំណើរការរូបសាស្ត្រ និងមេកានិកផ្សេងទៀត។

៤-រសជាតិអប់ដោយផ្សែងធម្មជាតិ។

៥-ទឹក និងអំបិល។

៦-ទឹកហូប។

៧-អំបិល (សូដ្យូមក្លរីត ឬប៉ូតាស្យូមក្លរីត ដែលជាធាតុផ្សំមូលដ្ឋាន ហើយប្រើជាទូទៅសម្រាប់ការកែច្នៃម្ហូបអាហារ)។

៨-ការរៀបចំប្រើប្រាស់ពពួកមីក្រូសរីរាង្គ និងអង់ស៊ីម។

៩-ការរៀបចំពពួកមីក្រូសរីរាង្គ និងអង់ស៊ីមមួយចំនួន សម្រាប់ប្រើជាទូទៅនៅក្នុងការកែច្នៃម្ហូបអាហារ ការលើកលែងតែការកែច្នៃពីសារពាង្គកាយកែច្នៃសេនេទិច។

១០-សារធាតុរ៉ែច្រើនប្រភេទ (រួមទាំងសារធាតុបន្ទាប់បន្សំ) វីតាមីន អាស៊ីតអាមីណូ អាស៊ីតខ្លាញ់ចាំបាច់ និងបណ្តុំសមាសធាតុអាសូតផ្សេងទៀត។

១១-ត្រូវបានអនុញ្ញាតឱ្យប្រើតែក្នុងករណីស្របច្បាប់ និងមានតម្រូវការចាំបាច់ក្នុងការរៀបចំអាហារប៉ុណ្ណោះ។

## តារាងទី៤៖ បញ្ជីសារធាតុគីមីសម្រាប់សម្អាត និងសម្លាប់មេរោគ ឧបករណ៍ ដែលអាចប៉ះផ្ទាល់ជាមួយអាហារ

| ផលិតផល | កំណត់សម្គាល់ |
|---|---|
| អាស៊ីតអាសេទិក ( Acetic Acid) | |
| អាកុល អេទីល (អេតាណុល) ( Alcohol, Ethyl (Ethanol) | |
| អាកុល អ៊ីសូប្រូពីល (អ៊ីសូប្រូប៉ាណុល) Alcohol, isopropyl (isopropanol) | |
| កាល់ស្យូមអ៊ីដ្រុកស៊ីត (កំបោរក្រលាយ) Calcium hydroxide (slaked lime) | |
| កាល់ស្យូមអ៊ីប៉ូក្លរីត (Calcium hypochlorite) | |
| កាល់ស្យូមអុកស៊ីត (កំបោរឆាប់រលាយ) Calcium oxide ( quicklime ) | |
| កំបោរក្លរីត (កាល់ស្យូមអុកស៊ីក្លរីត កាល់ស្យូមក្លរីត និង កាល់ស្យូមអ៊ីដ្រុកស៊ីត) (Chloride of lime ( calcium oxychloride, calcium chloride, and calcium | |
| ក្លរីនឌីអុកស៊ីត (Chlorine dioxide) | |
| អាស៊ីតស៊ីទ្រីក (Citric acid) | |
| អាស៊ីតហ្វ័រមិក Formic acid | |
| អ៊ីដ្រូសែនពែអុកស៊ីត Hydrogen peroxide | |
| អាស៊ីតឡាក់ទីក Lactic acid | |
| ប្រេងឆាប់រលាយ ចម្រាញ់ពីរុក្ខជាតិធម្មជាតិ Natural essences of plants | |
| អាស៊ីតអុកសាលីត Oxalic acid | |
| អូសូន Ozone | |



NYRS TN

| | |
|---|---|
| អាស៊ីតប៉ារ៉ាសេទិក Peracetic acid | |
| អាស៊ីតផូស្វ័រិក Phosphoric acid | |
| សារធាតុចម្រាញ់ចេញពីរុក្ខជាតិ Plant extracts | |
| សាប៊ូប៉ូតាស្យូម Potassium soap | |
| សូដ្យូមកាបូណាត Sodium carbonate | |
| សូដ្យូមអ៊ីដ្រុកស៊ីតសូដាមានលក្ខណៈកាត់ដូចជាអាស៊ីត ) Sodium hydroxide ( caustic soda ) | |
| សូដ្យូមអ៊ីប៉ូក្លរីត Sodium hypochlorite | ឧទាហរណ៍ ដូចជាសារធាតុរាវកាត់ឱ្យសជ្រះ |
| សាប៊ូសូដ្យូម Sodium soap | |

## តារាងទី៥៖ សារធាតុជំនួយក្នុងការកែច្នៃ ដែលអាចប្រើក្នុងផលិតផលកសិកម្មសរីរាង្គ

| សារធាតុ | លក្ខណៈពិសេស |
|---|---|
| **សម្រាប់ផលិតផលមានប្រភពពីរុក្ខជាតិ** | |
| ទឹកស្អាត: Water | |
| កាល់ស្យូមក្លរីត: Calcium chloride | សារធាតុសម្រាប់បង្កក |
| កាល់ស្យូមកាបូណាត: Calcium carbonate | |
| កាល់ស្យូមអ៊ីដ្រុកស៊ីត: Calcium hydroxide | |
| កាល់ស្យូមស៊ុលផាត: Calcium sulphate | |
| ម៉ាញ៉េស្យូមក្លរីត (ឬ នីហ្គារី): Magnesium chloride (or nigari) | សារធាតុសម្រាប់បង្កក |
| ប៉ូតាស្យូមកាបូណាត: Potassium | |
| ឧស្ម័នកាបូនិច: Carbon dioxide | |
| អាសូត: Nitrogen | |
| អេតាណុល: Ethanol | សារធាតុរំលាយ |
| អាស៊ីតតានីក: Tannic acid | ជំនួយក្នុងការចម្រោះ |
| ស៊ុតសអាប៊ុយមីន: Egg white albumin | |
| កាសេអ៊ីន: Casein | |
| សារធាតុអន្ទិល: Gelatine | |
| អ៊ីស៊ីងក្លាស: Isinglass | |
| ប្រេងបន្លែ: Vegetable Oils | |
| ស៊ីលីកុងឌីអុកស៊ីត: Silicon dioxide | ជាសារធាតុខាប់អន្ទិល ឬសូលុយស្យុង អន្ទិល |
| កាបោនសកម្ម: Activated carbon | |
| តាល់: (Talc) Talc | |

| | |
|---|---|
| ប៊ែនតូនីត: Bentonite | |
| កៅឡាំង: Kaolin | |
| ផូស៊ីលអាតូមីត: Diatomaceous earth | |
| ពែលីត: Perlite | |
| សំបកខ្យង Hazelnut shells | |
| ក្រមួនឃ្មុំ: Beeswax | |
| ក្រមួន: Carnauba wax | |
| អាស៊ីតស៊ុលផួរិក: Sulphuric acid | ការកែតម្រូវ pH ញែកយកទឹកចេញក្នុង ផលិតកម្ម ស្ករស |
| សូដ្យូមអ៊ីដ្រុកស៊ីត: Sodium hydroxide | ការកែតម្រូវ pH នៅក្នុងផលិតកម្មស្ករស |
| អាស៊ីត និងអំបិលតាតារិក (សូដ្យូម និងប៉ូតាស្យូមតាត្រាត): Tartaric acid and salts (Sodium and Potassium tartrate) | |
| សូដ្យូមកាបូណាត: Sodium carbonates | ផលិតកម្មស្ករស |
| ជាតុផ្សំធ្វើពីសមាសជាតុសំបកឈើ: Preparations of bark components | |
| ប៉ូតាស្យូមអ៊ីដ្រុកស៊ីត: Potassium hydroxide | ការកែតម្រូវ pH នៅក្នុងការកែច្នៃស្ករស |
| អាស៊ីតស៊ីទ្រីក: Citric acid | ការកែតម្រូវ pH |
| តានីន Tannin | |
| អាស៊ីតឡាក់ទីក: Lactic acid | |
| អាស៊ីតម៉ាលីក: Malic acid | |
| សារជាតុខ្លាញ់ពណ៌លឿងត្នោតឡេស៊ីទីន: Lecithin | |
| អុកស៊ីសែន: Oxygen | |

**ការរៀបចំដោយប្រើពពួកមីក្រូសរីរាង្គ និងអង់ស៊ីម**

១-ការរៀបចំពពួកមីក្រូសរីរាង្គ និងអង់ស៊ីមមួយចំនួនសម្រាប់ប្រើជាទូទៅនៅក្នុងការកែច្នៃម្ហូបអាហារ លើកលែងតែការកែច្នៃពីសារពាង្គកាយកែច្នៃសេ្បណេទិច ។

២-ការអនុញ្ញាតឱ្យប្រើប្រាស់ពពួកមីក្រូសរីរាង្គ និងអង់ស៊ីមត្រូវផ្អែកលើអនុលោមភាពនៃវិធានកសិកម្មសរីរាង្គកម្ពុជានេះ។

**ការចម្រាញ់សារធាតុអាចធ្វើបានតែក្នុងករណីជាមួយ** ទឹក អេតាណុល ប្រេងរុក្ខជាតិ និងខ្លាញ់ទឹកខ្មេះ ឧស្ម័នកាបូនិច និងអាសូត។

ឧបសម្ព័ន្ធទី២នៃប្រកាសលេខ...១៦៣.......ប្រក.កសក ចុះថ្ងៃទី១៦ខែ...មករា...ឆ្នាំ២០២០

## ស្តីពីរូបសញ្ញាជាតិ
## សម្រាប់អនុវត្តក្នុងផលិតកម្ម និងការកែច្នៃបឋមដំណាំសៀង

## គំរូរូបសញ្ញាជាតិសម្គាល់ការអនុវត្តវិធានកសិកម្មសរីរាង្គកម្ពុជា

### ១. លក្ខណៈរូបចន្តនៃរូបសញ្ញាជាតិ

- ពាក្យ កសិកម្មសរីរាង្គ ( 12 khmer OS Muol Light )
- ពាក្យ CAM ORGANIC ( Font Poplar Std Blue, CAM:size= 61.63pt, ORGANIC: size=38.75pt )
- ពាក្យ CAMBODIAN ORGANIC AGRICULTURE ( Font Myriad Pro, size = 61.63pt )
- រង្វង់ផ្ចិតខាងក្រៅ = ១៣ ស.ម
- រង្វង់ផ្ចិតខាងក្នុង = ១២.៥ ស.ម

### ២. អត្ថន័យនៃរូបសញ្ញាជាតិ

- រូបដើមត្នោតមានពណ៌ខ្មៅ គឺតំណាងគុណភាព ភាពស្ថិតស្ថេរយូរអង្វែង គង់វង្ស ជាពិសេសជាដើមឈើតំណាងឱ្យជាតិខ្មែរ។
- រូបស្លឹកត្នោតចំនួនបីជាង តំណាងឱ្យក្រុមដំណាំទាំងបីគឺ៖ ដំណាំស្រូវ ដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្ម។
- ផ្ទៃពណ៌បៃតង តំណាងឱ្យបរិស្ថាន និងធម្មជាតិដ៏ល្អបរិសុទ្ធ ស្មោះត្រង់ ជឿជាក់គ្នា ហើយក៏បញ្ជាក់អំពីគុណភាពផលិតផលសរីរាង្គគ្មានសារធាតុគីមី។

- ខ្សែវ័ណ្ឌរាងជារង្វង់ពណ៌បៃតងជុំវិញ តំណាងឱ្យការគ្រប់គ្រងផលិតកម្ម និងផលិតផលកសិកម្មសរីរាង្គទូទាំងប្រទេស។